កម្មវិធីទប់ស្កាត់បឋម

ភាសាខ្មែរ

មាតិកា

សេចក្តីណែនាំ

02 មាតិកា

04 ទិដ្ឋភាពទូទៅនៃកម្មវិធី

07 ទិដ្ឋភាពទូទៅនៃអង្គការមូលនិធិអេ២១

09 ទិដ្ឋភាពទូទៅនៃអំពើជួញដូរមនុស្ស

12 ទ្រង់ទ្រាយកម្មវិធី និងមាតិកាកម្មវិធី

គោលការណ៍ណែនាំសម្រាប់អ្នកសម្របសម្រួល

16 វគ្គទី ០១៖ គុណតម្លៃ និងសិទ្ធិកុមារ

20 វគ្គទី ០២៖ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងគ្មានសុវត្ថិភាព

24 វគ្គទី ០៣៖ ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច

គោលការណ៍ណែនាំអំពីសកម្មភាព

29 វគ្គទី ០១

43 វគ្គទី ០២

53 វគ្គទី ០៣

ឯកសារយោង និងធនធានផ្សេងៗ

63 ឯកសារយោងផ្សេងៗ

65 ធនធានផ្សេងៗ

រក្សាសិទ្ធិដោយអង្គការមូលនិធិអេ២១ ឆ្នាំ២០២០ ។
មូលនិធិអេ២១ ជាអង្គការមិនស្វែងរកប្រាក់ចំណេញនិងមិនមែនរដ្ឋាភិបាល។
សូមរក្សាសិទ្ធិគ្រប់យ៉ាង គ្មានផ្នែកណាមួយនៃសម្ភារដែលត្រូវបានការពារដោយសិទ្ធិរបស់
អ្នកនិពន្ធនេះត្រូវបានផលិតឡើងវិញ ឬប្រើប្រាស់ក្នុងទម្រង់ណាមួយ ឬតាមមធ្យោបាយ
ផ្សេងៗក្នុងការបោះពុម្ពផ្នែកទាំងអស់ ឬផ្នែកណាមួយដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍
អក្សរពីម្ចាស់កម្មសិទ្ធិឡើយ។
សំណើសុំការអនុញ្ញាតគួរតែត្រូវបានផ្ញើតាមរយៈអ៊ីមែលមកកាន់អាសយដ្ឋាន info@A21.org;

ប្រធានបទ៖ ការសុំអនុញ្ញាតការរក្សាសិទ្ធិ។
ការបដិសេធ៖ រាល់តួរអង្គនិងរឿងរ៉ាវនៅក្នុងធនធានសម្ភារៈ នេះគឺជាការប្រឌិត។
ឈ្មោះដែលមាននៅក្នុងករណីនីមួយៗមិនមានលក្ខណៈជាបុគ្គលឬតំណាងឱ្យ
បុគ្គលជាក់លាក់ណាមួយឡើយ ។ឈ្មោះតំបន់នានាដែលបានរៀបរាប់នៅ
ក្នុងករណីនីមួយៗមិនបង្ហាញពីទម្រង់នៃការជួញដូរមនុស្សណាមួយកើតឡើង
នៅក្នុងតំបន់ទាំងនោះទេ។

ទិដ្ឋភាពទូទៅ

កម្មវិធីទប់ស្កាត់បឋម

យើងខ្ញុំសូមអរគុណលោកអ្នកដែលបានជ្រើសរើសក្នុងការសិក្សាស្វែងយល់បន្ថែមអំពីអំពើជួញដូរមនុស្ស និងវិធានការដើម្បីទប់ស្កាត់។ ដោយប្រើវិធីសាស្រ្តផ្តោតទៅលើកុមារ កម្មវិធីនេះមានគោលបំណងធ្វើឱ្យកុមារចេះសហការគ្នាជាមួយមិត្តភក្តិរបស់ពួកគេដោយមានការដឹកនាំពីអ្នកសម្របសម្រួល។ កម្មវិធីនេះត្រូវបានរៀបរៀងឡើងដើម្បីផ្តល់អំណាចដល់កុមារ និងដើម្បីគាំទ្រដល់សំលេងរបស់ពួកគេព្រមទាំងបង្រៀនពួកគេឱ្យមានសមត្ថភាពក្នុងការសម្រេចចិត្តដើម្បីការពារខ្លួនគេ និងអ្នកដទៃ។ សូមរីករាយក្នុងការធ្វើវាដោយខ្លួនឯង ហើយកុំស្ទាក់ស្ទើរក្នុងការសួរសំណួរមកកាន់យើង៖ A21.ORG/CONTACT យើងខ្ញុំទន្ទឹងរង់ចាំស្តាប់អំពីលទ្ធផលដែលលោកអ្នកសម្រេចបានក្នុងការតស៊ូដើម្បីសេរីភាព។

តើអ្វីគឺជាគោលបំណងរបស់យើង ?

០១ កំណត់ និងការពារគុណតម្លៃព្រមទាំងសិទ្ធិមនុស្សរបស់កុមារ។

០២ ទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព និងការកេងប្រវ័ញ្ច។

០៣ ផ្តល់ជូននូវធនធានជានានា និងរបៀបនៃការតស៊ូមតិសម្រាប់កុមារ។

តើកម្មវិធីនេះមានរយៈពេលប៉ុន្មាន ?

កម្មវិធីនេះមានវគ្គសិក្សារយៈពេល០១ម៉ោងចំនួន០៣វគ្គដែលអាចបត់បែនបាន ហើយអាចឆ្លើយតបទៅនឹងបរិបទរបស់អ្នកចូលរួម និងរយៈពេលនៃថ្នាក់រៀនរបស់អ្នក។

តើកម្មវិធីនេះបង្កើតឡើងសម្រាប់នរណា ?

កម្មវិធីនេះបង្កើតឡើងសម្រាប់កុមារដែលមានអាយុចាប់ពី៦ឆ្នាំដល់១២ឆ្នាំហើយកម្មវិធីនេះអាចសម្របសម្រួលជាមួយទំហំនៃក្រុមណាមួយក៏បាន។

ការសម្របសម្រួលកម្មវិធី

កម្មវិធីនេះអាចនឹងត្រូវបានប្រើប្រាស់នៅតាមសហគមន៍ឬនៅក្នុងសាលារៀនដើម្បីបង្រៀនកុមារអំពីតម្លៃរបស់ពួកគេក្នុងនាមជាមនុស្សជាតិហើយជួយឱ្យពួកគេយល់ថាទោះបីជាពួកគេជាអនីតិជននៅឡើយក៏ពួកគេនៅតែជាបុគ្គលដែលមានសិទ្ធិស្វ័យសម្រេចរបស់ខ្លួន។ ធនធានទាំងនេះផ្តោតទៅលើជំនាញបំណិនជីវិតប្រកបដោយប្រសិទ្ធភាព តម្លៃផ្ទាល់ខ្លួន សេចក្តីថ្លៃថ្នូរ អំណាចនៃការសម្រេចចិត្ត ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការណែនាំអំពីអំពើជួញដូរនិងការកេងប្រវ័ញ្ច និងសុវត្ថិភាពតាមតាមប្រព័ន្ធអ៊ីនធឺណែត។

ស្តង់ដាររបស់កម្មវិធី

ប្រធានបទដែលមានភាពស្មុគស្មាញត្រូវបានធ្វើឱ្យមានលក្ខណៈសមស្របទៅតាមអាយុ និងត្រូវបានធ្វើឱ្យស្របតាមបរិបទនៃស្តង់ដារអប់រំរបស់ប្រទេសនីមួយៗ កម្មវិធីនេះត្រូវបានសាកល្បងមុនគេបង្អស់នៅតំបន់អាស៊ីអាគ្នេយ៍ជាមួយកុមារជាង ៧០០០នាក់ ហើយមាតិកាទាំងអស់នៃកម្មវិធីនេះត្រូវបានធ្វើឱ្យស្របទៅតាមមូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា B.E.២៥៥១(២០០៨) របស់ប្រទេសថៃ។ កម្មវិធីនេះត្រូវបានគេវាយតម្លៃក្នុងភាពជាដៃគូតាមរយៈការសិក្សាស្រាវជ្រាវផ្នែកសិក្សាធិការជាមួយសាកលវិទ្យាល័យ *Virginia Commonwealth University* ដែលចាប់ផ្តើមនៅឆ្នាំ ២០១៩ ។ កម្មវិធីកម្រិតស្តង់ដារអន្តរជាតិនេះបានរក្សានូវសមត្ថភាពស្នូលសំខាន់ៗ ហើយអាចត្រូវបានធ្វើឱ្យមានលក្ខណៈទៅតាមបរិបទរបស់ប្រទេសនីមួយៗ ដើម្បីឆ្លើយតបទៅនឹងបទដ្ឋានអប់រំ និងតម្រូវការសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការចែកចាយបន្ត។

កម្មវិធីបណ្តុះបណ្តាល

ដើម្បីបង្ហាញពីសកម្មភាពមួយចំនួនរបស់កម្មវិធីយើងបានបង្កើតធនធានវីដេអូអប់រំដែលមានលក្ខណៈជាស៊េរី និងស្លាយសម្រាប់បញ្ជាំងដល់អ្នកសម្របសម្រួលតាមប្រព័ន្ធអ៊ីនធឺណែត ការបណ្តុះបណ្តាលនេះរួមបញ្ចូលទាំងការថតវីដេអូ និងសម្លេងអំពីទិដ្ឋភាពទូទៅនៃវគ្គនីមួយៗ និងសកម្មភាពដែលត្រូវបានសម្របសម្រួលដោយគ្រូនៅក្នុងថ្នាក់រៀន ហើយវាក៏អាចត្រូវបានប្រើប្រាស់ជាធនធានសម្រាប់ហ្វឹកហ្វឺនដល់គ្រូបង្គោលផងដែរ ។ ដើម្បីទទួលបានការបណ្តុះបណ្តាលពេញលេញសូមចូលទៅកាន់៖
A21.ORG/TRAINING

សំណើសុំអនុសាសន៍

យើងខ្ញុំចង់ឮអំពីអ្នកវិញខណៈពេលដែលកម្មវិធីនេះត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយមិនគិតថ្លៃ យើងខ្ញុំស្នើសុំឱ្យលោកអ្នកជួយត្រួតពិនិត្យមើល និងវាយតម្លៃអំពីផលប៉ះពាល់នៃកម្មវិធីនេះ។ បន្ទាប់ពីលោកអ្នកបានសម្របសម្រួលកម្មវិធីនេះរួចហើយ សូមមេត្តាជួញបំពេញទម្រង់នៃការស្ទង់មតិខ្លីនេះ៖
A21.ORG/EDUCATION-SURVEY

10
8
9
7
5
6
4
2
3
1
START

ទិដ្ឋភាពទូទៅ

ទិដ្ឋភាពទូទៅនៃអង្គការមូលនិធិអេ២១

តើយើងជានរណា ?

អង្គការមូលនិធិអេ២១ គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញអន្តរជាតិ ដែលបានប្តេជ្ញាចិត្តក្នុងការលុបបំបាត់អំពើជួញដូរមនុស្សតាមរយៈយុទ្ធសាស្ត្រប្រតិបត្តិរួមមាន៖ ការទប់ស្កាត់ ការជួយសង្គ្រោះ និងការស្តារឡើងវិញ។

សូមអានបន្ថែមអំពីការងាររបស់យើងនៅជុំវិញពិភពលោក

A21.ORG/ABOUT

តើអ្វីគឺជាបេសកកម្មរបស់យើង ?

លុបបំបាត់ទាសភាពនៅគ្រប់ទីកន្លែង និងជារៀងរហូត។

តើយើងធ្វើការនៅកន្លែងណាខ្លះ ?

អង្គការមូលនិធិអេ២១ បានចាប់ផ្តើមបង្កើតឡើងនៅក្នុងឆ្នាំ ២០០៨ ហើយចាប់តាំងពីពេលនោះមកយើងបានបង្កើតការិយាល័យមូលដ្ឋាន មណ្ឌលសហគមន៍ មជ្ឈមណ្ឌលតស៊ូមតិសម្រាប់កុមារ និងរដ្ឋបាលមូលដ្ឋាននៅទូទាំងពិភពលោក។

សម្រាប់ព័ត៌មានពេញលេញអំពីទីតាំងនៃអង្គការមូលនិធិអេ២១
សូមចូលទៅកាន់៖ **A21.ORG/WHERE-WE-WORK**

ទិដ្ឋភាពទូទៅ

អំពើជួញដូរមនុស្ស

ការការពារគឺជាគន្លឹះក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអំពើរំលោភសិទ្ធិមនុស្ស។ យើងជឿជាក់ក្នុងការបំពាក់បំប៉នសមត្ថភាពដល់មនុស្សជំនាន់ក្រោយនូវជំនាញដើម្បីផ្តល់នូវអំណាច និងពីរបៀបការពារខ្លួនគេពីការរំលោភបំពាន និងលទ្ធភាពនៃការកេងប្រវ័ញ្ចទាំងនេះ។

តើអ្នកដឹងដែរឬទេ ?

- គេបានប៉ាន់ប្រមាណថាសព្វថ្ងៃនេះ នៅគ្រប់ទីកន្លែងមានមនុស្សចន្លោះពី ២០,៩ លាន ទៅ ៤០,៣ លាននាក់ត្រូវបានស្ថិតនៅក្នុងស្ថានភាពជាទាសភាព។ [១] ជនរងគ្រោះម្នាក់ក្នុងចំណោម ០៤ នាក់ដែលរងគ្រោះដោយទាសភាពសម័យទំនើបគឺជាកុមារ។[២]

- មានការកើនឡើងយ៉ាងខ្លាំងអំពីចំនួនជនអន្តោប្រវេសន៍អន្តរជាតិនៅទូទាំងពិភពលោក។ [៣] ជនចំណាកស្រុកនៅតែស្ថិតក្នុងចំណោម "សមាជិកដែលងាយរងគ្រោះបំផុតនៃសង្គម" ដែលស៊ូទ្រាំនឹងការរំលោភសិទ្ធិមនុស្ស ការរំលោភបំពាន និងការរើសអើង។ [៤]

- ១០% នៃចំនួនប្រជាជនសរុបនៅក្នុងពិភពលោករស់នៅក្រោមចំណូលតិចជាង ១.៩០ ដុល្លារក្នុងមួយថ្ងៃ។ [៥] ប្រជាជនភាគច្រើនដែលរស់នៅក្នុងភាពក្រីក្រមិនមានលទ្ធភាពទទួលបាននូវការអប់រំ។ ពួកគេរស់នៅតាមតំបន់ជនបទ ធ្វើការងារដែលមិនមានសុវត្ថិភាព (មិនមានសុវត្ថិភាព និងមិនមានស្ថេរភាព) ហើយជាងពាក់កណ្តាលនៃពួកគេគឺជាអ្នកដែលមានអាយុក្រោម ១៨ ឆ្នាំ។ [៦] មានកុមារ ក្មេងជំទង់ និងយុវជននៅទូទាំងពិភពលោកចំនួន ២៦៤លាននាក់មិនបានចូលរៀន។ [៧]

- មានយុវជនចំនួន ១០៣ លាននាក់នៅទូទាំងពិភពលោកខ្វះជំនាញអក្ខរកម្មហើយជាង ៦០ភាគរយនៃពួកគេគឺជាស្ត្រី។ [៨]

- ជារៀងរាល់ឆ្នាំមានកុមារ និងក្មេងជំទង់ចំនួន ២៤៦ លាននាក់នៅជុំវិញពិភពលោកត្រូវបានរាយការណ៍ថាពួកគេបានទទួលរងនូវអំពើហិង្សា ឬការសម្លុតធ្វើបាបនៅឯសាលារៀន។ [៩]

- យោងតាមស្ថិតិនៅលើពិភពបានបង្ហាញថាអត្រានៃការធ្វើអត្តឃាតគឺជាមូលហេតុចំបងទី២ នៃការស្លាប់ក្នុងចំណោមអ្នកដែលមានអាយុចន្លោះពី ១៥ ទៅ ២៩ ឆ្នាំ ការស្រាវជ្រាវក៏បានបង្ហាញផងដែរថាអាកប្បកិរិយានៃការធ្វើអត្តឃាតកើតឡើងពីកត្តាហានិភ័យមួយចំនួនដែលពុំមានការការពារ ។ [១០]

តើអ្នកដឹងទេ ?

- ចំនួនកុមារនៅក្នុងសកលលោកដែលមិនបានចូលរៀនបានធ្លាក់ចុះជិតពាក់កណ្ដាលចាប់តាំងពីឆ្នាំ ២០០០ ។ [១១] វាគឺជាការចាំបាច់ណាស់ក្នុងការរក្សាកុមារឱ្យបានចូលរៀនព្រោះការអប់រំក៏ត្រូវបានគេចាត់ទុកថាជា “មធ្យោបាយមួយដែលមានឥទ្ធិពល និងមានភាពប្រាជប្រជាបំផុតសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព” ។ [១២]
- ការរក្សាភាពត្រឹមត្រូវនៃការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពគឺជាសមត្ថភាពក្នុងការរកឱ្យឃើញនូវការធ្វើចំណាកស្រុកដែលមិនមានភាពប្រក្រតី និងការហាមឃាត់សកម្មភាពឆ្លងដែនដោយខុសច្បាប់ដូចជាការជួញដូរមនុស្ស ការរត់ពន្ធមនុស្ស ការធ្វើចំណាកស្រុក និងសកម្មភាពពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌនានា។
- ការនិយាយអំពីបញ្ហាដែលអាចកាត់បន្ថយអត្រាធ្វើអត្តឃាត និងរោគសញ្ញានៃការធ្លាក់ទឹកចិត្តផ្សេងៗ។ជាញឹកញាប់មនុស្សដែលធ្វើអត្តឃាតខ្លួនឯង ពួកគេពិតជាមិនមានបំណងធ្វើឱ្យខ្លួនឯងឈឺចាប់នោះទេ ប៉ុន្តែដោយសារពួកគេព្យាយាមប្រាស្រ័យទាក់ទងជាមួយនឹងអារម្មណ៍ដែលជាក់លាក់ដូចជាទុក្ខព្រួយ ភាពអស់សង្ឃឹម និងកំហឹងជាដើម។ [១៣]
- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១៦ដោយកម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ។ ជារួមកម្មវិធីអភិវឌ្ឍប្រកបដោយចិរភាពនេះមានអន្តរគោលបំណងចំនួន១៧ដូចជាការកាត់បន្ថយភាពក្រីក្រ ការលើកម្ពស់គុណភាពអប់រំ ការលើកកម្ពស់សមាសភាពយេនឌ័រ ការទប់ស្កាត់អំពើជួញដូរមនុស្ស ការលើកកម្ពស់សេវាសុខាភិបាល និងការលើកកម្ពស់សុខុមាលភាព (ឧទាហរណ៍ សុខភាពផ្លូវចិត្ត) ដែលមានគោលដៅធ្វើឱ្យពិភពលោកទាំងមូល ដើរលើផ្លូវរីកចម្រើន និងការអភិវឌ្ឍន៍ប្រកបដោយចិរភាព។ [១៤]
- ស្ថិតិទាំងនេះបង្ហាញថាទោះបីជាមានរឿងរ៉ាវអាក្រក់ៗ ជាច្រើនដែលបានកើតឡើងនៅក្នុងពិភពលោកយើងនេះ ប៉ុន្តែនៅពេលដែលយើងចាប់ផ្តើមប្រយុទ្ធយ៉ាងសកម្មចំពោះបញ្ហាទាំងនោះ យើងនឹងចាប់ផ្តើមមើលឃើញពីការផ្លាស់ប្តូរ ។ក្តីសង្ឃឹមរបស់យើងគឺថា តាមរយៈកម្មវិធីនេះគឺយើងនឹងចាប់ផ្តើមអប់រំកុមារ និងអ្នកសម្របសម្រួលដើម្បីបង្កើតឱ្យមានការផ្លាស់ប្តូរ។ យើងជឿជាក់ថាការលុបបំបាត់អំពើជួញដូរ និងការកេងប្រវ័ញ្ចមនុស្សគឺអាចធ្វើទៅបានក្នុងដំណរជីវិតរបស់យើងហើយកម្មវិធីនេះគឺជាការឈានមួយជំហានទៀតដើម្បីឆ្ពោះទៅរកការសម្រេចបាននូវក្តីសង្ឃឹមនេះ។ សូមអរគុណចំពោះការចូលរួមធ្វើដំណើរជាមួយពួកយើង។

គ្មាននរណាម្នាក់អាចធ្វើអ្វីគ្រប់យ៉ាងបាន តែម្នាក់ឯងនោះទេប៉ុន្តែយើងម្នាក់ៗអាចធ្វើអ្វីមួយបាន ។

— លោកស្រី គ្រីស្ទីន ខេន គឺជាអ្នកតស៊ូមតិ
របស់អង្គការមូលនិធិអេ២១

ទ្រង់ទ្រាយនៃកម្មវិធី

តើកម្មវិធីនេះត្រូវបានរៀបចំឡើងយ៉ាងដូចម្ដេច?

- សេចក្ដីណែនាំសម្រាប់អ្នកសម្របសម្រួល៖ ផ្ដល់ការណែនាំជាជំហានៗដើម្បីជួយឱ្យអ្នកដឹកនាំក្រុមរបស់អ្នកឆ្លងកាត់វគ្គនីមួយៗដោយជោគជ័យ។
- សេចក្ដីណែនាំសម្រាប់ធ្វើសកម្មភាព ៖ ផ្ដល់សកម្មភាពសម្រាប់វគ្គនីមួយៗ។ យើងសូមណែនាំឱ្យអ្នកពិនិត្យមើលសកម្មភាពនីមួយៗជាមុនសិនពីព្រោះសម្ភារខ្លះត្រូវការព្រីន ឬបោះពុម្ពចេញ ត្រូវការកាត់ និងត្រូវការរៀបទុកចំជាមុន។ ជួនកាលវាតម្រូវឱ្យមានការរៀបចំសម្ភារទាំងនោះទុកជាមុន។
- សេចក្ដីណែនាំអំពីការប្រើប្រាស់ធនធាន៖ ផ្ដល់ធនធាននិងព័ត៌មានបន្ថែមសម្រាប់អ្នក និងក្រុមរបស់អ្នកដើម្បីបន្តសិក្សាស្វែងយល់បន្ថែមទៀតអំពីការការពារខ្លួនពីអំពើជួញដូរមនុស្ស។

តើវគ្គសិក្សាទាំងនេះត្រូវបានរៀបចំឡើងយ៉ាងដូចម្ដេច?

ផ្នែករៀបចំ

ការរៀបចំគឺជាផ្នែកមួយដែលមានសារៈសំខាន់នៅក្នុងវគ្គនីមួយៗដែលត្រូវបានរៀបរៀងឡើងដើម្បីជួយដល់អ្នកសម្របសម្រួលក្នុងការឆ្លើយនឹងសំណួរផ្សេងៗ៖ ដើម្បីបញ្ចប់វគ្គសិក្សានេះប្រកបដោយជោគជ័យ តើយើងត្រូវការអ្វីខ្លះ?

- សេចក្ដីថ្លែងអំពីគោលបំណងចំនួន ០៣ ច្បាប់
- សំណួរសំខាន់ៗចំនួន ០៣ សំណួរ
- លក្ខខណ្ឌសំខាន់ៗចំនួន ០៦
- សម្ភារៈ (ប្រព័ន្ធផ្សព្វផ្សាយនិងឧបសម្ព័ន្ធ)

ផ្នែកបង្រៀន

ការបង្រៀនគឺជាផ្នែកមួយដែលផ្ដោតសំខាន់នៅក្នុងវគ្គនីមួយៗដែលត្រូវបានរៀបចំឡើងដើម្បីបំពាក់ប៉ុនសមត្ថភាពដល់អ្នកសម្របសម្រួលក្នុងការឆ្លើយសំណួរផ្សេងៗ៖

តើសិស្សត្រូវយល់ដឹងពីអ្វីខ្លះ ហើយអាចធ្វើអ្វីបានខ្លះនៅពេលដែលពួកគេបញ្ចប់វគ្គនីមួយៗ?
តើមានជំហានដែលចាំបាច់អ្វីខ្លះនៅក្នុងវគ្គបណ្ដុះបណ្ដាលនេះដើម្បីលើកទឹកចិត្តសិស្សរបស់ខ្ញុំឱ្យមានការចូលរួម?

តើវគ្គសិក្សានីមួយៗមានអ្វីខ្លះ ?

មានកម្រិតនៃការសិក្សាខុសគ្នាចំនួនពីរដែលត្រូវបានរៀបចំឡើងដើម្បីឱ្យសិស្សមានការចូលរួមទាំងនៅក្នុងក្រុមតូច និងក្រុមធំ។

ផ្នែកទី ០១ - សេចក្តីផ្តើម

- សំណួរសំខាន់ៗ
- សកម្មភាពណែនាំ

ផ្នែកទី ០២ - អន្តរកម្ម (កម្រិត ០១)

- អន្តរកម្មសកម្មភាព៖ មានសកម្មភាពពីរដែលត្រូវបានបង្កើតឡើងដើម្បីឱ្យអ្នកសិក្សាកម្រិតដំបូងបានធ្វើបន្តិចម្តងៗ។ សកម្មភាពទាំងនោះបង្ហាញអំពី ការចងចាំ ការយល់ដឹង និងការកម្រិតការអនុវត្តជាមូលដ្ឋាន ។

ផ្នែកទី ០៣ ការបណ្តុះគំនិត (កម្រិត ០២)

- ការអំពាវនាវឱ្យធ្វើសកម្មភាព៖ មានសកម្មភាពដែលជាជម្រើសចំនួន បួន (ឧទាហរណ៍៖ តន្ត្រី សិល្បៈ ការសម្តែងនិងការសរសេរបែបច្នៃប្រឌិត) សម្រាប់ការឆ្លើយតបផ្ទាល់មាត់ ឬតាមរយៈការសរសេរ ដែលអាចជ្រើសរើសយកវិធីសាស្តធ្វើជាក្រុមឬជាដៃគូ។សកម្មភាពទាំងនេះបានជួយបង្កើនកម្រិតនៃការរៀនសូត្រតាមរយៈការអនុវត្ត ការវិភាគ និង ការវាយតម្លៃលើមាតិកានៃវគ្គសិក្សា។

មាតិកាកម្មវិធី

វគ្គទី ០១

គុណតម្លៃនិងសិទ្ធិកុមារ

កុមារត្រូវការដឹងថាពួកគេមានតម្លៃ ហើយសំលេងរបស់ពួកគេពិតជាមានសារៈសំខាន់។ វគ្គនេះនឹងជួយកុមារឱ្យស្គាល់អំពីសារៈសំខាន់នៃគុណតម្លៃ និងសិទ្ធិជាមូលដ្ឋានរបស់ពួកគេមិនត្រឹមតែនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេប៉ុណ្ណោះទេប៉ុន្តែថែមទាំងមាននៅក្នុងជីវិតរបស់អ្នកដទៃផងដែរ។

វគ្គទី ០២

ចំណាកស្រុកដែលមានសុវត្ថិភាព

គោលបំណងនៃវគ្គនេះគឺដើម្បីបំពាក់បំប៉នចំណេះដឹងដល់សិស្ស និងឪពុកម្តាយរបស់ពួកគេ ជាមួយនឹងឧបករណ៍ដើម្បីបែងចែករវាងការធ្វើចំណាកស្រុកដែលមានសុវត្ថិភាពនិងគ្មានសុវត្ថិភាព។ ពេលខ្លះប្រជាជនធ្វើចំណាកស្រុក ដោយមានភាពមិនប្រក្រតី និងគ្មានសុវត្ថិភាពដែលធ្វើឱ្យពួកគេខ្វះនូវការការពារដែលជាកត្តានាំឱ្យងាយរងគ្រោះទៅនឹងអំពើជួញដូរនិងការកេងប្រវ័ញ្ច។

វគ្គទី ០៣

អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច

វគ្គសិក្សានេះនឹងជួយឱ្យយើងស្វែងយល់អំពីរបៀបដែលការជួញដូរ និងការកេងប្រវ័ញ្ចគឺជាឧក្រិដ្ឋកម្មដែលបានកើតឡើងនៅគ្រប់ប្រជាជាតិនៅជុំវិញពិភពលោក។ វគ្គនេះនឹងបង្រៀនកុមារអំពីវិធីដើម្បីកំណត់អត្តសញ្ញាណជនដែលបង្ករគ្រោះថ្នាក់ និងជួយឱ្យពួកគេដឹងថាតើនរណាដែលពួកគេគួរនិយាយជាមួយ និងពីរបៀបដែលការរក្សាការសម្ងាត់នាំឱ្យមានសុវត្ថិភាព និងគ្មានសុវត្ថិភាព។

ពាក្យគន្លឹះ៖

ការយល់ដឹងអំពីពាក្យគន្លឹះទាំងនេះគឺជាមូលដ្ឋានគ្រឹះនៃការសិក្សាអំពីកម្មវិធីនេះ។ ពាក្យគន្លឹះទាំងនេះត្រូវបានរួមបញ្ចូលនៅក្នុងវគ្គសិក្សាទាំងបីនេះ។

- **ការរើសអើង៖** គឺជាការប្រព្រឹត្តដោយអយុត្តិធម៌ឬលំអៀងទៅលើក្រុម ឬបុគ្គលនីមួយៗដោយផ្អែកទៅលើកត្តាមួយចំនួនដូចជា ភេទ ពូជសាសន៍ ជនជាតិដើម អាយុ សាសនានិង / ឬបញ្ញា ។
- **ការកេងប្រវ័ញ្ច៖** គឺជាទង្វើនៃការប្រើប្រាស់អ្វីមួយ ឬនរណាម្នាក់តាមរបៀបឃោរឃៅ ឬអយុត្តិធម៌ដើម្បីផលប្រយោជន៍ខ្លួន។
- **សិទ្ធិមនុស្ស៖** គឺជាគោលការណ៍ ច្បាប់ សង្គម និងក្រមសីលធម៌នៃសេរីភាពសម្រាប់មនុស្សទាំងអស់ដែលរួមបញ្ចូលទាំងសិទ្ធិរបស់កុមារផង។
- **ភាពអយុត្តិធម៌៖** គឺជាការរំលោភលើសិទ្ធិរបស់បុគ្គល និងទង្វើអយុត្តិធម៌ ។
- **យុត្តិធម៌៖** ភាពស្មើគ្នា ឬការប្រព្រឹត្តដោយយុត្តិធម៌ ។
- **មនុស្សដែលមិនគួរឲ្យទុកចិត្ត (ឬមនុស្សមានកលល្បិច)៖** ជាមនុស្សដែលធ្លាប់ស្គាល់ ឬជាមនុស្សចម្លែកណាម្នាក់ដែលធ្វើអ្វីមួយដោយគ្មានការអនុញ្ញាត (ឧទាហរណ៍៖ ការនិយាយ ឬការប៉ះពាល់) ឬប្រើការបោកបញ្ឆោត (ឧទាហរណ៍៖ ការនិយាយកុហក និងប្រើកលល្បិច) ដែលធ្វើឱ្យនរណាម្នាក់មានអារម្មណ៍មិនល្អ ឬត្រូវបានគេកេងបន្លំ ។

សេចក្តីណែនាំសម្រាប់អ្នកសម្របសម្រួល

PREPARE

វគ្គទី ០១

គុណតម្លៃ និងសិទ្ធិកុមារ

គំនិតសំខាន់

មនុស្សគ្រប់គ្នាមានតម្លៃ។
មនុស្សគ្រប់គ្នាសុទ្ធតែសំខាន់។
កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការការពារ។

គោលបំណង

០១ គុណតម្លៃ និងសិទ្ធិ៖ ការណែនាំ និងអនុវត្តគោលគំនិតសំខាន់ៗ នៃគុណតម្លៃ និងសិទ្ធិកុមារជាមូលដ្ឋាន។

០២ ការសម្រេចចិត្ត និងការការពារ៖ កំណត់ការសម្រេចចិត្តដែលត្រឹមត្រូវ និងមិនត្រឹមត្រូវសម្រាប់ជំនាញបំណិនជីវិតដែលមានសុវត្ថិភាពដើម្បីធ្វើសកម្មភាពប្រកបដោយសុវត្ថិភាព។

០៣ សមត្ថភាព៖ ការវិភាគតម្លៃ និងស្ថានភាពសិទ្ធិមនុស្សដើម្បីទទួលស្គាល់ពីសក្តានុពល និងសមត្ថភាពរបស់កុមារក្នុងការប្រាស្រ័យទាក់ទង ការគិត ការដោះស្រាយបញ្ហា ចំណេះដឹងបច្ចេកទេស និងជំនាញបំណិតជីវិត។

សំនួរសំខាន់ៗ

- តើអ្វីជាសិទ្ធិកុមារ ?
- តើមានវិធីណាខ្លះដែលមនុស្សម្នាក់ៗអាចបង្ហាញឱ្យអ្នកដទៃមើលឃើញពីតម្លៃរបស់ពួកគេ ?
- តើមនុស្សដែលគួរឱ្យទុកចិត្ត និងមនុស្សដែលមានល្បិចកលមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេចខ្លះ ?
- តើការសម្រេចចិត្តប្រកបដោយសុភវិនិច្ឆ័យ និងឈ្លាសវៃអាចការពារកុមារពីគ្រោះថ្នាក់បានយ៉ាងដូចម្តេច ?
- តើមានវិធីអ្វីខ្លះក្នុងការទទួល និងផ្តល់ព័ត៌មានដើម្បីលុបបំបាត់ការឆ្លើយតបបែបអវិជ្ជមានចំពោះសិទ្ធិមនុស្ស និងតម្លៃ ?
- តើកុមារអាចយកឈ្នះឧបសគ្គនានាតាមរយៈការអនុវត្តគុណតម្លៃ ហេតុផល និងការវិនិច្ឆ័យរបស់ពួកគេដោយរបៀបណា ?

ពាក្យគន្លឹះ

- **លក្ខណៈសកលៈ** គឺជាកម្មសិទ្ធិ ឬអនុវត្តជាទូទៅ និងសម្រាប់មនុស្សទាំងអស់។
- **ទំនិញៈ** គឺជាផលិតផលសេដ្ឋកិច្ច ឬផលិតផលដែលអាចទិញ ឬលក់បាន។
- **សមភាពៈ** ត្រូវបានគេចាត់ទុកថាវាជាភាពស្មើភាពគ្នានៅក្នុងសិទ្ធិមនុស្ស និងឱកាស។
- **សមធម៌ៈ** យុត្តិធម៌ ឬការធានានូវសិទ្ធិទទួលបានឱកាសស្មើភាពគ្នាដើម្បីទទួលបាននូវសមភាព។
- **ការគោរពៈ** ការឱ្យតម្លៃចំពោះ ឬការយល់ដឹងពីតម្លៃនៃឧត្តមភាពរបស់មនុស្សណាម្នាក់ ដើម្បីបង្ហាញការគោរពចំពោះភាពខុសគ្នារបស់មនុស្សម្នាក់ៗដូចជាការចូលចិត្ត ការឱ្យតម្លៃ និងគុណសម្បត្តិរបស់គេ។
- **គុណតម្លៃៈ** សារៈសំខាន់ ឬតម្លៃរូបិយវត្ថុ ឬគុណប្រយោជន៍នៃរបស់អ្វីមួយ ឬអាកប្បកិរិយារបស់មនុស្សម្នាក់ដែលកំណត់ពីរបៀបដែលពួកគេប្រព្រឹត្ត។

សកម្មភាព

- **ការណែនាំ**
  ការឱ្យតម្លៃទៅលើតម្លៃ (សកម្មភាព ០១ក)

- **អន្តរកម្ម**
  កម្រងសិទ្ធិទាំងបួនរបស់កុមារ (សកម្មភាព ០១ខ)
  សមភាពនិងសមធម៌ (សកម្មភាព ០១គ)

- **ការបំផុសគំនិត**
  ការអំពាវនាវឱ្យធ្វើសកម្មភាព (សកម្មភាព ០១ឃ)

TEACH

ជំហានទី ០១

ការណែនាំ

ការនិយាយៈ យើងនឹងស្វែងយល់អំពីគោលគំនិតសំខាន់ៗនៃគុណតម្លៃ និងសិទ្ធិរបស់កុមារ។អ្នកឱ្យតម្លៃទៅលើរបស់អ្វីមួយដែលមានសារៈសំខាន់ចំពោះអ្នក។ សូមគិតអំពីផលិតផលមួយ ឬវត្ថុមួយ ឬផលិតផលមួយដែលអ្នកមានហើយវាមានតម្លៃចំពោះអ្នក (ឧទាហរណ៍ៈ ទូរស័ព្ទចល័ត ស្បែកជើង ប្រដាប់ប្រដាលេង) និងសូមចែករំលែកពីមូលហេតុដែលអ្នកគិតថាវាមានសារៈសំខាន់ចំពោះអ្នកនិងថាតើវាមានតម្លៃសម្រាប់អ្នកយ៉ាងដូចម្តេច។ របស់ទាំងនេះត្រូវបានគេហៅថាជាទំនិញ។ ពួកវាគឺជាទំនិញដែលអាចទិញ ឬលក់បាន។

សួរថាៈ " តើគុណតម្លៃមានអ្វីខ្លះ ?"

គំរូចំលើយៈ គុណតម្លៃមានសារៈសំខាន់ដូចជាតម្លៃរូបិយវត្ថុ ឬរបស់ដែលមានប្រយោជន៍នៃអ្វីមួយ។ អាកប្បកិរិយារបស់មនុស្សម្នាក់ដែលកំណត់ពីរបៀបដែលពួកគេប្រព្រឹត្ត។ (ឧទាហរណ៍ៈ មានដូចជាភាពគួរឱ្យទុកចិត្ត ការគោរព ទំនួលខុសត្រូវ ការអធ្យាស្រ័យល្អ ការគោរពប្រតិបត្តិ ភាពស្មោះត្រង់ និងភាពសប្បុរស) ។ គុណតម្លៃមិនមែនជារបស់របរទេ។ គុណតម្លៃគឺជាអ្វីដែលយើងមិនអាចទិញ ឬលក់បានទេ។ គុណតម្លៃទាំងនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈរបៀបដែលអ្នកគិត និងធ្វើ។

ធ្វើៈ គុណតម្លៃ (សកម្មភាព ០១ក)

ជំហានទី ០២
ការណែនាំ

និយាយ: អង្គការសហប្រជាជាតិ (អ. ស. ប) បានចេញសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស [១៥] ដើម្បីបង្ហាញពីគុណតម្លៃនិងសារៈសំខាន់របស់មនុស្ស។ វាត្រូវបានរៀបចំឡើងដើម្បីការពារសិទ្ធិរបស់ប្រជាជននៃប្រជាជាតិទាំងអស់នៅក្នុងសកលលោក។ ការរៀនអំពីគុណតម្លៃ និងសិទ្ធិមនុស្សជាសកលអាចជួយឱ្យយើងចេះគោរពគ្នាទៅវិញទៅមក។ កិច្ចការពារកុមារ និងសិទ្ធិរបស់ពួកគេគឺមានសារៈសំខាន់ខ្លាំងណាស់ដូច្នេះហើយបានជាអង្គការសហប្រជាជាតិបានបង្កើតឯកសារជាក់លាក់អំពីសិទ្ធិកុមារទាំងនេះមក។ កុមារទាំងអស់ត្រូវបានទទួលស្គាល់ដោយអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធកុមារ ។[16] ប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោកបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ នេះមានន័យថាពួកគេបានឯកភាពថាកុមារទាំងអស់ដោយមិនគិតពី "ឋានៈក្នុងសង្គម" មានសិទ្ធិដូចគ្នាក្នុងការទទួលបាននូវបរិយាកាសនៃការការពារមិនថានៅលើប្រព័ន្ធអ៊ីនធឺណិត ឬនៅក្រៅប្រព័ន្ធអ៊ីនធឺណិតនោះទេ សេចក្តីថ្លែងការណ៍ជាសកលរបស់អង្គការសហប្រជាជាតិទាក់ទងទៅនឹងសិទ្ធិកុមារបានចែងថា "មិនថាពួកគេជានរណា រស់នៅកន្លែងណា ឪពុកម្តាយធ្វើអ្វីពួកគេនិយាយភាសាអ្វី កាន់សាសនាអ្វី មិនថាពួកគេជាក្មេងប្រុស ឬក្មេងស្រី ហើយវប្បធម៌របស់ពួកគេជាអ្វីមិនថាពួកគេមានពិការភាព ហើយទោះបីពួកគេជាអ្នកមាន ឬអ្នកក្រក៏ដោយ" គឺគ្មានកុមារណាម្នាក់ត្រូវបានគេប្រព្រឹត្តដោយអយុត្តិធម៌ចំពោះសិទ្ធិជាមូលដ្ឋានរបស់គេណាមួយបានឡើយ (យូ. អិន. ស៊ី. អ. ស៊ី. ១៩៨៩) សេចក្តីថ្លែងការណ៍នេះគឺដើម្បីការពារកុមារពីភាពអយុត្តិធម៌ និងការរំលោភសិទ្ធិរបស់ពួកគេ និងជួយឱ្យកុមារមានសុវត្ថិភាពរួចផុតពីគ្រោះថ្នាក់ផ្សេងៗ។

សួរថា៖ " តើកុមារជាមនុស្សដែលមានអាយុៈប៉ុន្មាន ?"

គំរូចម្លើយ៖ គឺជាមនុស្សដែលមានអាយុៈតិចជាង ឬក្រោម ១៨ឆ្នាំ។

សួរថា៖ " តើសិទ្ធិមនុស្សគឺជាអ្វី ?"

គំរូចំលើយ៖ សិទ្ធិមនុស្សគឺជាគោលការណ៍ច្បាប់ សង្គម និងសីលធម៌នៃសេរីភាពសម្រាប់មនុស្សទាំងអស់ដែលរួមមានទាំងសិទ្ធិកុមារផង។ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ សិទ្ធិក្នុងការសម្រាកនិងការលំហែ សិទ្ធិក្នុងការអប់រំ និងសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខរបស់មនុស្ស។

សួរថា៖ " តើកុមារទាំងអស់មានសិទ្ធិដូចគ្នាដែរឬទេ ?"

គំរូចម្លើយ៖ ត្រូវហើយ! កុមារទាំងអស់មានសិទ្ធិដូចៗគ្នា។ សិទ្ធិមនុស្សគឺជាសិទ្ធិជាសកលដែលមនុស្សគ្រប់គ្នាៗមាន។

ធ្វើ៖ កម្រងសិទ្ធិទាំងបួនរបស់កុមារ (សកម្មភាព ០១ខ)

និយាយ: សិទ្ធិ និងការទទួលបានសិទ្ធិគឺមានភាពខុសគ្នានោះហើយជាមូលហេតុដែលថាទោះបីជាមនុស្សគ្រប់រូបមានសិទ្ធិដូចគ្នាក៏ដោយក៏មិនប្រាកដថាពួកគេទទួលបានការអនុវត្តសិទ្ធិរបស់ពួកគេដូចៗគ្នាដែរ។

សួរថា៖ “ តើអ្នកគិតថាសិទ្ធិរបស់អ្នកបានធ្វើឱ្យមានភាពខុសប្លែកគ្នានៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នកដែរឬទេ ? ដោយរបៀបណា ?”

គំរូចម្លើយ៖ បាទ/ចាស
សិទ្ធិរបស់អ្នកអនុញ្ញាតឱ្យអ្នកទទួលបានអាហារ និងទឹកស្អាតដើម្បីធ្វើឱ្យអ្នកមានសុខភាពល្អ និងអនុញ្ញាតឱ្យអ្នកទទួលបានការអប់រំដើម្បីជួយឱ្យអ្នកដឹងថាតើអ្នកត្រូវធ្វើអ្វីបន្ទាប់ពីរៀនចប់ ហើយផ្តល់ឱ្យអ្នកនូវឱកាសដើម្បីឈោងចាប់ក្តីសុបិន្តរបស់អ្នក។

- **និយាយ**: វាជាមានសំខាន់ណាស់ដែលអ្នកត្រូវតែចងចាំថាអ្នកមានតម្លៃទោះបីជាអ្នកជានរណាក៏ដោយ។ មនុស្សគ្រប់រូបមានតម្លៃហើយគ្រប់គ្នាសមនឹងទទួលបានយុត្តិធម៌ (ត្រូវបានទទួលនូវការប្រព្រឹត្តដោយយុត្តិធម៌)។ សិទ្ធិមនុស្សអនុញ្ញាតឱ្យកុមារទទួលបាននូវរបស់របរចាំបាច់ដើម្បីរស់នៅពេញមួយជីវិតដែលប្រកបដោយសុវត្ថិភាព ភាពរីករាយ និងមានសុខភាពល្អ ។

- **និយាយ**: វិធីមួយដែលអាចលុបបំបាត់ការឆ្លើយតបបែបអវិជ្ជមានចំពោះសិទ្ធិមនុស្ស និងតម្លៃគឺត្រូវបន្តការលើកកម្ពស់យុត្តិធម៌តាមរយៈការធ្វើឱ្យមានសមភាព និងលុបបំបាត់នូវរាល់គំនិតនៃការរើសអើងតាមរយៈការលើកកម្ពស់សមធម៌។

ធ្វើ៖ សមភាពនិងសមធម៌ (សកម្មភាព ០១គ)

សួរថា៖ “ តើអ្វីគឺជាភាពខុសគ្នារវាងសមភាព និងសមធម៌ ?”

គំរូចំលើយ៖ សមភាពមានគោលបំណងលើកកម្ពស់ភាពយុត្តិធម៌ដោយការផ្តល់ឱ្យគ្រប់គ្នានូវសិទ្ធិស្មើៗគ្នា ។ ទោះជាយ៉ាងណាក៏ដោយមនុស្សម្នាក់ៗរស់នៅក្នុងស្ថានភាពផ្សេងៗគ្នាដែលជួនកាលអាចធ្វើឱ្យពួកគេមានការលំបាកក្នុងការទទួលបានសិទ្ធិទាំងនេះដោយសេរី នោះហើយជាមូលហេតុដែលយើងត្រូវធ្វើឱ្យមានសមធម៌ ។ សមធម៌គឺជាការផ្តល់ឱ្យមនុស្សគ្រប់គ្នានូវអ្វីដែលពួកគេត្រូវការ (ឱកាស ឬ ធនធាន ។ល។) ដើម្បីទទួលបាននូវរបស់ ឬអ្វីមួយដូចគ្នា។ ជួនកាលវាមានន័យថាមនុស្សត្រូវបានគេផ្តល់ឱ្យនូវអ្វីដែលប្លែកឬច្រើនដើម្បីទទួលបានលទ្ធផលដូចគ្នា។ ឧទាហរណ៍៖ ជនពិការអាចត្រូវការជំនួយបន្ថែមរួមមាន រទេះរុញ ឧបករណ៍ជំនួយការស្តាប់ ឬអវយវៈសិប្បនិម្មិត ដែលអាចជួយឱ្យពួកគេបំពេញការងារបានដូចមនុស្សធម្មតាដែរ។

ជំហានទី ០៣
ការបំផុសគំនិត

- **និយាយ**: យើងបានសិក្សាអំពីសិទ្ធិ តម្លៃ និងវិធីការពារខ្លួនយើងរួចហើយ។ ឥឡូវនេះយើងនឹងអនុវត្តនូវអ្វីដែលយើងបានរៀនហើយបង្កើតវិធីសាស្ត្រផ្សេងៗ ដើម្បីជម្រុញទឹកចិត្តនិងអប់រំដល់អ្នកដ៏ទៃទៀត។

ធ្វើ៖ ការអំពាវនាវឱ្យធ្វើសកម្មភាព (សកម្មភាពទី០១)

វគ្គទី ០២

ចំណាកស្រុកដែលមានសុវត្ថិភាព

PREPARE

គំនិតសំខាន់

ការធ្វើចំណាកស្រុកគឺជាផ្នែកដ៏ធំមួយនៃពិភពលោករបស់យើង។ ប្រជាជនធ្វើចំណាកស្រុកដោយសារមូលហេតុផ្សេងៗគ្នា។ ការធ្វើចំណាកស្រុកដោយសុវត្ថិភាពអាចជួយសង្គ្រោះជីវិតមនុស្សបាន។

គោលបំណង

០១ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព៖ ណែនាំនិងអនុវត្តគោលគំនិតសំខាន់ៗនៃការធ្វើចំណាកស្រុកដោយសុវត្ថិភាព។

០២ ការសម្រេចចិត្ត និងការការពារ៖ ការប្រៀបធៀបការសម្រេចចិត្តនៃការធ្វើចំណាកស្រុកដែលមានសុវត្ថិភាព និងគ្មានសុវត្ថិភាព។

០៣ សមត្ថភាព៖ វិភាគស្ថានភាពនៃការធ្វើចំណាកស្រុកដើម្បីទទួលស្គាល់ពីសក្តានុពល និងសមត្ថភាពរបស់កុមារក្នុងការប្រាស្រ័យទាក់ទង ការគិតការដោះស្រាយបញ្ហា ចំណេះដឹងបច្ចេកទេស និងជំនាញបំណិតជីវិត។

សំនួរសំខាន់ៗ

- តើការធ្វើចំណាកស្រុកគឺជាអ្វី ?
- តើភាពស្រដៀងគ្នានិងភាពខុសគ្នារវាងការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងគ្មានសុវត្ថិភាពមានអ្វីខ្លះ ?
- តើមានហានិភ័យអ្វីខ្លះដែលអាចកើតឡើងក្នុងកំឡុងពេលធ្វើចំណាកស្រុកជាមួយមនុស្សមិនគួរអោយទុកចិត្ត ឬមនុស្សដែលមានកលល្បិច ?
- តើការធ្វើការសម្រេចចិត្តប្រកបដោយសុភវិនិច្ឆ័យ និងភាពឈ្លាសវៃអាចជួយផ្តល់ព័ត៌មានអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពបានយ៉ាងដូចម្តេច ?
- តើមានវិធីអ្វីខ្លះដើម្បីទទួល និងផ្តល់ព័ត៌មានអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ?
- តើអ្នកលុបបំបាត់បញ្ហានិងឧបសគ្គក្នុងការធ្វើចំណាកស្រុកដោយប្រើហេតុផលនិងការវិនិច្ឆ័យដែលមានលក្ខណៈត្រឹមត្រូវបានយ៉ាងដូចម្តេច ?

ពាក្យគន្លឹះ

- **អន្តោប្រវេសន៍៖** គឺជាផ្លាស់ទីលំនៅពីប្រទេសមួយទៅកាន់ប្រទេសមួយផ្សេងទៀតជាអចិន្ត្រៃយ៍។
- **ការធ្វើចំណាកស្រុក៖** គឺជាចលនានៃការផ្លាស់លំនៅទីពីកន្លែងមួយទៅកាន់កន្លែងមួយទៀត។
- **ការធ្វើចំណាកស្រុកមិនប្រក្រតី“មិនមានសុវត្ថិភាព”៖** គឺជាសកម្មភាពនៃផ្លាស់ប្តូរទីកន្លែងពីប្រទេសមួយទៅប្រទេសមួយទៀតដោយគ្មានឯកសារស្របច្បាប់ត្រឹមត្រូវ។
- **ការធ្វើចំណាកស្រុកដោយសុវត្ថិភាព៖** គឺជាសកម្មភាពនៃការធ្វើចំណាកស្រុកទៅកន្លែងណាមួយដែលប្រកបដោយសុវត្ថិភាព និងស្របច្បាប់។
- **ជនភៀសខ្លួន៖** ជានរណាម្នាក់ដែលបានផ្លាស់ទៅរស់នៅប្រទេសថ្មីដើម្បីគេចវេសពីបញ្ហាដែលកើតមាននៅក្នុងប្រទេសកំណើតរបស់ពួកគេ។
- **ការធ្វើចំណាកស្រុកតាមរដូវកាល៖** គឺជាចលនានៃការផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀតក្នុងគោលបំណងធ្វើកសិកម្ម ប្រមូលផល ឬដោយសារការប្រែប្រួលអាកាសធាតុ។

សកម្មភាព

- **ការណែនាំ**
  ប្រភេទនៃការធ្វើចំណាកស្រុក (សកម្មភាព ០២ក)
- **អន្តរកម្ម**
  ការធ្វើចំណាកស្រុកមានសុវត្ថិភាពឬគ្មានសុវត្ថិភាព? (សកម្មភាព ០២ខ)ល្បែងចំណាកស្រុក (សកម្មភាព ០២គ)
- **ការបំផុសគំនិត**
  ការអំពាវនាវឱ្យធ្វើសកម្មភាព (សកម្មភាពទី ០២ឃ)

TEACH

ជំហានទី ០១

ការណែនាំ

និយាយ: ការធ្វើចំណាកស្រុកគឺកើតមាននៅគ្រប់ទីកន្លែង។ វាគឺជាចលនាបំលាស់ទីពីកន្លែងមួយទៅកន្លែងមួយ។ ជារៀងរាល់ឆ្នាំមានគ្រួសារនិងមនុស្សរាប់លាននាក់នៅជុំវិញពិភពលោកចង់ធ្វើចំណាកស្រុកឬត្រូវការចាកចេញពីផ្ទះរបស់ពួកគេដោយសារហេតុផលផ្សេងៗ។នៅពេលដែលនរណាម្នាក់ផ្លាស់ប្តូរទីលំនៅទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋបរទេសណាមួយនោះត្រូវបានគេហៅថាជាជនអន្តោប្រវេសន៍។ មានកត្តាសំខាន់ពីរដែលទាក់ទងទៅនឹងការធ្វើចំណាកស្រុកគឺកត្តាជំរុញ និងកត្តាអូសទាញ។ អ្នកខ្លះធ្វើចំណាកស្រុកដោយសារជម្រើសនៅពេលដែលពួកគេត្រូវបានអូសទាញទៅកាន់ប្រទេសផ្សេងទៀតដើម្បីទទួលបាននូវឱកាសល្អប្រសើរដូចជាការងារឬដើម្បីធ្វើអោយកម្រិតជីវភាពរបស់ពួកគេប្រសើរឡើង។អ្នកផ្សេងទៀតត្រូវបានជំរុញ ឬបង្ខំចិត្តឱ្យធ្វើចំណាកស្រុកដោយសារតែសង្គ្រាម ការកេងប្រវ័ញ្ច ភាពក្រីក្រ ឬគ្រោះមហន្តរាយធម្មជាតិ (ឧទាហរណ៍ដូចជា ទឹកជំនន់ អគ្គិភ័យ និង ការរញ្ជួយដី)។ ការធ្វើចំណាកស្រុកក៏អាចត្រូវបានជះឥទ្ធិពលដោយសារកត្តាផ្សេងទៀតរួមមាន កង្វះអាហារនិងទីជម្រក បញ្ហាបរិស្ថាន បញ្ហានយោបាយ និងសេដ្ឋកិច្ច បញ្ហាអសន្តិសុខ និងភាពខុសគ្នានៃវប្បធម៌។ ជារឿយៗ ការធ្វើចំណាកស្រុកត្រូវបានផ្សារភ្ជាប់ទៅ នឹងបំណងប្រាថ្នានិងក្តីសង្ឃឹមចង់បាននូវសេរីភាព លក្ខណ្ឌរស់នៅនិង/ឬការងារដែលល្អប្រសើរយុត្តិធម៌និងការទទួលបាននូវសិទ្ធិស្មើៗគ្នា ។

សួរថា៖ “ នៅពេលយើងគិតអំពីទស្សនៈនៃការធ្វើចំណាកស្រុកតើអ្នកដឹងទេថាសត្វអ្វីខ្លះដែលធ្វើការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត ?ហេតុអ្វីបានជាពួកគេធ្វើការបំលាស់ទី ?”

គំរូចំលើយ៖ សត្វបក្សីធ្វើការបំលាស់ទីដើម្បីស្វែងរកចំណីអាហារ និងទឹក និងដើម្បីស្វែងរកអាកាសធាតុដែលល្អប្រសើរជាងមុន។

សួរថា៖ “ តើអ្នកស្គាល់នរណាម្នាក់ដែលបានផ្លាស់ទីលំនៅទៅកន្លែងផ្សេងដែរឬទេ ? ហេតុអ្វីបានជាពួកគេធ្វើចំណាកស្រុក ?”

គំរូចំលើយ៖ ត្រូវហើយ! មិត្តរបស់ខ្ញុំបានធ្វើចំណាកស្រុកដោយសារតែឪពុករបស់នាងមានការងារថ្មីនៅទីក្រុងមួយផ្សេងទៀត។

សួរថា៖ “ តើពួកគេត្រូវចំណាយពេលប៉ុន្មានដើម្បីទៅដល់ទីតាំងថ្មីរបស់ពួកគេ ? តើពួកគេបានធ្វើដំណើរជាក្រុមដែរឬទេ ?”

គំរូចំលើយ៖ នាងត្រូវការពេលពីរបីថ្ងៃដើម្បីទៅដល់ទីតាំងថ្មីរបស់ពួកគេហើយនាងបានធ្វើដំណើរជាមួយគ្រួសារនាង។

ធ្វើ៖ ប្រភេទនៃការធ្វើចំណាកស្រុក (សកម្មភាព ០២ក)

ជំហានទី ០២
អន្តរកម្ម

និយាយ៖ នៅឆ្នាំកន្លងទៅថ្មីៗនេះមានការកើនឡើងយ៉ាងខ្លាំងនៃជនអន្តោប្រវេសន៍អន្តរជាតិនៅទូទាំងពិភពលោក។អ្នកទំនងជាស្គាល់មនុស្សណាស់ម្នាក់ដែលបានធ្វើចំណាកស្រុករួចហើយ។ ប្រសិនបើនៅទេក្នុងមួយជីវិតរបស់នេះអ្នកគង់តែនឹងបានជួបនរណាម្នាក់ដែលបានធ្វើចំណាកស្រុកជាមិនខាន។ជនចំណាកស្រុកនៅតែស្ថិតក្នុងចំណោម “សមាជិកសង្គមដែលងាយរងគ្រោះបំផុត...ការស៊ូទ្រាំនឹងការរំលោភបំពានសិទ្ធិមនុស្ស ការរំលោភបំពានផ្នែករាងកាយ និងការរើសអើង”។ មនុស្សខ្លះធ្វើចំណាកស្រុកដោយសារតែមានការរើសអើងទៅលើ សញ្ជាតិ ពូជសាសន៍ និងសាសនា។ នៅពេលខ្លះពួកគេត្រូវបានបង្ខំឱ្យចាកចេញពីប្រទេសកំណើតរបស់ពួកគេដើម្បីរត់គេចពីសង្គ្រាម ការធ្វើទុក្ខបុកម្នេញឬដោយសារតែគ្រោះមហន្តរាយធម្មជាតិ។កត្តានេះអាចធ្វើឱ្យមនុស្សម្នាក់ផ្លាស់ទីលំនៅរបស់ខ្លួនហើយក្លាយទៅជាជនភៀសខ្លួន។ អ្នកផ្សេងទៀតធ្វើចំណាកស្រុកដោយផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀតក្នុងគោលបំណងដើម្បីធ្វើកសិកម្ម ដើម្បីប្រមូលផល ឬដោយសារតែមានការប្រែប្រួលអាកាសធាតុ។ការធ្វើចំណាកស្រុកបែបនេះត្រូវបានគេស្គាល់ថាជាការធ្វើចំណាកស្រុកតាមរដូវកាល ។ ដូច្នេះការស្វែងយល់អំពីប្រភេទនៃការធ្វើចំណាកស្រុកនៅថ្ងៃនេះនឹងជួយពន្យល់អ្នកអំពីរបៀបដែលមនុស្សមួយចំនួនត្រូវបានគេរំលោភសិទ្ធិនៅក្នុងកំឡុងពេលនៃការធ្វើចំណាកស្រុក។ ហើយនឹងជួយឱ្យអ្នកដឹងថាមានភាពអយុត្តិធម៌បែបណាខ្លះដែលគ្រួសារទាំងនោះបានស៊ូទ្រាំដោយសារតែមនុស្សដែលមានកលល្បិចព្យាយាមលួងលោមឱ្យពួកគេធ្វើចំណាកស្រុកដោយខុសច្បាប់។

សួរថា៖ “ តើការធ្វើចំណាកស្រុកមានប៉ុន្មានប្រភេទ ហើយតើមានវិធីណាខ្លះដែលប្រជាជនធ្វើចំណាកស្រុក ?”

គំរូចំលើយ៖ អ្នកអាចធ្វើចំណាកស្រុកដោយជិះយន្តហោះ ជិះទូក ដើរថ្មើជើង ឬជិះឡាន។

សួរថា៖ “ តើអ្វីដែលអាចធ្វើឱ្យការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព ? ”

គំរូចំលើយ៖ គឺការធ្វើចំណាកស្រុកដោយគ្មានលិខិតឆ្លងដែន គ្មានទិដ្ឋាការ ឬការលួចឆ្លងកាត់ព្រំដែនដោយខុសច្បាប់។

ធ្វើ៖ ការធ្វើចំណាកស្រុកដែលមានសុវត្ថិភាព ឬគ្មានសុវត្ថិភាព ? (សកម្មភាព ០២ខ)

សួរថា៖ “ តើបញ្ហានៃការធ្វើចំណាកស្រុកវាជាប់ពាក់ព័ន្ធជាមួយនឹងអ្នកដែរឬទេ ប្រសិនបើអ្នកមិនដែលធ្វើចំណាកស្រុកផង ? បើជាប់ពាក់ព័ន្ធតើហេតុអ្វី / បើមិនជាប់ពាក់ព័ន្ធតើហេតុអ្វី ? ”

គំរូចំលើយ៖ ទោះបីអ្នកមិនធ្វើចំណាកស្រុកក៏ដោយក៏អ្នកប្រហែលជាត្រូវការជួយដល់អ្នកដែលបានធ្វើចំណាកស្រុក ឬអ្នកដែលចង់ធ្វើចំណាកស្រុក។

ឧទាហរណ៍៖ សមាជិកគ្រួសារ ឬមិត្តភក្តិ ឬជាផ្នែកនៃការងាររបស់អ្នក ដូចជាគ្រូបង្រៀន មេធាវី វេជ្ជបណ្ឌិត ឬជាប៉ូលីស ជាដើម។

សួរថា៖ “តើអ្នកធ្លាប់លឺរឿងរ៉ាវរបស់នរណាម្នាក់ដែលបានធ្វើចំណាកស្រុកដោយសុវត្ថិភាពឬអ្នកដែលបានធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាពទេ ? តើអ្នកចង់ចែករំលែករឿងនេះដែរឬទេ ? ”

គំរូចំលើយ៖ ឪពុកខ្ញុំចាប់ផ្ដើមការងារថ្មីមួយហើយពួកយើងត្រូវផ្លាស់ប្ដូរទីលំនៅតាំងតែពីពេលខ្ញុំនៅតូចម្លេះ។ យើងមានសុវត្ថិភាពពីព្រោះពួកយើងបានធ្វើចំណាកស្រុកជាមួយគ្រួសារទាំងមូល។

ធ្វើ៖ ល្បែងចំណាកស្រុក (សកម្មភាព ០២គ)សុវត្ថិភាព ? (សកម្មភាព ០២ខ)

▶ **និយាយ៖** វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលយើងត្រូវចងចាំថាការធ្វើចំណាកស្រុកអាចធ្វើឱ្យពិភពលោករបស់យើងមានការផ្លាស់ប្ដូរហើយក៏អាចជួយសង្គ្រោះជីវិតមនុស្សបានប្រសិនបើការធ្វើចំណាកស្រុកនោះប្រកបដោយសុវត្ថិភាព។ ពេលខ្លះវិធីនៃការធ្វើចំណាកស្រុករបស់ប្រជាជនគឺមានលក្ខណៈខុសគ្នា និងមានហេតុផលផ្សេងៗគ្នាផងដែរ វាមិនមែនតែងតែកើតឡើងដោយសារតែជម្រើសនោះទេ។

ជំហានទី ០៣

ការបំផុសគំនិត

▶ **និយាយ៖** យើងបានសិក្សាអំពីលក្ខណៈនៃការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងគ្មានសុវត្ថិភាព ហើយនឹងមធ្យោបាយដើម្បីការពារខ្លួនយើងរួចហើយ។ ឥឡូវនេះយើងនឹងអនុវត្តនូវអ្វីដែលយើងបានរៀន ហើយបង្កើតវិធីដើម្បីជម្រុញទឹកចិត្តនិងអប់រំអ្នកដទៃ។

ធ្វើ៖ ការអំពាវនាវឱ្យធ្វើសកម្មភាព (សកម្មភាពទី ០២)

វគ្គទី ០៣

អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច

PREPARE

គំនិតសំខាន់

សព្វថ្ងៃនេះអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកើតមាននៅពាសពេញពិភពលោក។ ដើម្បីការពារកុមារពីការជួញដូរវាគឺជាការចាំបាច់ណាស់ដែរយើងត្រូវទទួលស្គាល់ពីភាពខុសគ្នារវាងអាថ៌កំបាំងដែលមានសុវត្ថិភាព និងគ្មានសុវត្ថិភាព។

គោលបំណង

០១ ទម្រង់នៃការជួញដូរមនុស្ស៖ ការណែនាំអំពីទម្រង់មូលដ្ឋាននៃការជួញដូរមនុស្ស។

០២ ហានិភ័យនិងយុទ្ធសាស្រ្តការពារ៖ កំណត់សក្តានុពលនៃការកេងប្រវ័ញ្ចនិងការជួញដូរមនុស្សចំពោះកុមារដើម្បីផ្តល់ចំណេះដឹងឱ្យពួកគេនិងឧបករណ៍ដើម្បីការពារខ្លួន។

០៣ សមត្ថភាព៖ ពិនិត្យមើលលើស្ថានភាពដែលមានសុវត្ថិភាពនិងគ្មានសុវត្ថិភាពក្នុងទម្រង់នៃការកេងប្រវ័ញ្ចដើម្បីទទួលស្គាល់ពីសក្តានុពលនិងសមត្ថភាពរបស់កុមារក្នុងការប្រាស្រ័យទាក់ទង ការគិត វិធីដោះស្រាយបញ្ហា និងជំនាញបំណិនជីវិត។

សំនួរសំខាន់ៗ

- តើការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគឺជាអ្វី?
- តើទម្រង់សំខាន់ៗនៃអំពើរជួញដូរមនុស្សមានអ្វីខ្លះ?
- តើមានហានិភ័យអ្វីខ្លះដែលអាចកើតមានចំពោះកុមារដែលត្រូវបានគេកេងប្រវ័ញ្ច?
- តើអ្វីទៅជាភាពខុសគ្នារវាងការប៉ះពាល់រាងកាយដែលសមរម្យ និងមិនសមរម្យ?
- ភាពខុសគ្នារវាងការសម្ងាត់ដែលមានសុវត្ថិភាព និងគ្មានសុវត្ថិភាពមានអ្វីខ្លះ?
- តើកុមារមានសិទ្ធិអ្វីខ្លះទាក់ទងនឹងរាងកាយរបស់ពួកគេ?

ពាក្យគន្លឹះ

- **អំពើជួញដូរមនុស្ស៖** គឺជាទម្រង់នៃការកេងប្រវ័ញ្ច ជាបទល្មើសឧក្រិដ្ឋ ជាការធ្វើអាជីវកម្មខុសច្បាប់លើរាងកាយរបស់មនុស្សក្នុងគោលបំណងកេងប្រវ័ញ្ចកម្លាំងពលកម្មដោយបង្ខំ និងការជួញដូរផ្លូវភេទ។ ការជួញដូរកុមារគឺជាការជួញដូរនរណាម្នាក់ដែលមានអាយុក្រោម១៨ឆ្នាំ។
- **ការកេងប្រវ័ញ្ចកុមារលើបណ្តាញអ៊ីនធឺណិត៖** ជារឿយៗការកេងប្រវ័ញ្ចកុមារនៅលើបណ្តាញអ៊ីនធឺណិតគឺតាមរយៈការប្រើប្រាស់រូបភាពមិនសមរម្យ (រូបអាក្រាត ឬហិង្សា)។
- **ការសម្ងាត់ដែលមានសុវត្ថិភាព៖** គឺជាព័ត៌មានដែលមានលក្ខណៈសម្ងាត់ ឬមិនត្រូវបានដឹងដោយអ្នកដទៃប៉ុន្តែទីបំផុតនឹងត្រូវបានបង្ហាញ ។(ឧទាហរណ៏៖ ការធ្វើឲ្យមានការភ្ញាក់ផ្អើល)។
- **អ្នកជួញដូរ៖** គឺជាមនុស្សដែលធ្វើអំពើជួញដូរ និង/ឬកេងប្រវ័ញ្ច លើមនុស្សដ៏ទៃផ្សេងទៀត។
- **ការសម្ងាត់ដែលគ្មានសុវត្ថិភាព៖** គឺជាព័ត៌មានដែលអាចធ្វើឱ្យនរណាម្នាក់ឈឺចាប់ឬរំលោភច្បាប់ ឬជាពត៌មានដែលធ្វើឱ្យនរណាម្នាក់មានអារម្មណ៍ភ័យខ្លាច ឬមិនស្រួលនិងមិនត្រូវបានគេដឹងថាជារឿងឯកជន ឬមិនត្រូវបានអ្នកដទៃដឹង(ត្រូវបានប្រាប់ថាកុំប្រាប់គេ)។
- **ភាពងាយរងគ្រោះ៖** គឺជាទីតាំងឬស្ថានភាពដែលមនុស្សណាម្នាក់ងាយទទួលឥទ្ធិពលពីគ្រោះថ្នាក់លើផ្នែករាងកាយនិងអារម្មណ៍របស់ពួកគេ។

សកម្មភាព

- **ការណែនាំ**
  ភាពខុសគ្នារវាងការរក្សាការសម្ងាត់ដែលមានសុវត្ថិភាព និង ការនិយាយចេញពី
  ការសម្ងាត់ដែលគ្មានសុវត្ថិភាព (សកម្មភាព ០៣ក)

- **អន្តរកម្ម**
  ការស្វែងយល់អំពីការកេងប្រវ័ញ្ច (សកម្មភាព ០៣ ខ)
  តើអ្នកនឹងធ្វើអ្វី? (សកម្មភាព ០៣ គ)

- **ការបំផុសគំនិត**
  ការអំពាវនាវឱ្យធ្វើសកម្មភាព (សកម្មភាព ០៣ ឃ)

TEACH

ជំហានទី ០១
ការណែនាំ

▶ **និយាយ៖** ថ្ងៃនេះយើងនឹងរៀនអំពីថាតើអំពើជួញដូរ និងកេងប្រវ័ញ្ចដែលជាបទល្មើសឧក្រិដ្ឋបានកើតឡើងនៅគ្រប់ប្រជាជាតិទាំងអស់នៅជុំវិញពិភពលោកយ៉ាងដូចម្តេច? យើងក៏នឹងរៀនពីវិធីដើម្បីកំណត់អត្តសញ្ញាណជនដែលគួរឱ្យគ្រោះថ្នាក់ដើម្បីការពារមនុស្សគ្រប់គ្នាពីភាពងាយរងគ្រោះ ។ យើងនឹងស្វែងយល់ថាតើនរណាដែលអ្នកអាចស្វែងរកជំនួយ ហើយថាតើការសម្ងាត់បែបណាដែលមានសុវត្ថិភាពឬគ្មានសុវត្ថិភាព។ ការកេងប្រវ័ញ្ច និងការជួញដូរមនុស្សកើតមានឡើងគឺដោយសារតែ "មនុស្សដែលមានកលល្បិច" ។ យើងដឹងហើយថាការរើសអើងនិងភាពក្រីក្របានបង្កើនឱ្យមានភាពងាយរងគ្រោះកាន់តែច្រើនឡើងហើយជនដែលងាយរងគ្រោះមិនមានអារម្មណ៍ថាមានសុវត្ថិភាពនៅក្នុងការដែលនិយាយប្រាប់ការពិតដល់អ្នកដទៃទោះបីជាគេដឹងថាអ្នកនោះគឺជាមនុស្សដែលអាចទុកចិត្តបានក៏ដោយ ។ពេលខ្លះ "មនុស្សដែលមានកលល្បិច" អាចជាអ្នកដែលត្រូវបានធ្វើពុតថាពួកគេស្រឡាញ់ និងការពារអ្នកដូចជាសមាជិកគ្រួសារឬមិត្តភក្តិរបស់អ្នកដែរ ហើយពេលខ្លះពួកគេក៏អាចជាមនុស្សចម្លែកផងដែរ។

▶ **និយាយ៖** ការជួញដូរនិងការកេងប្រវ័ញ្ចលើកុមារគឺពឹងផ្អែកជាសំខាន់ទៅលើការសម្ងាត់។ ដូច្នេះក្នុងនាមជាកុមារវាជាការសំខាន់ណាស់ដែលអ្នកត្រូវដឹងពីភាពខុសគ្នារវាងការសម្ងាត់ដែលមានសុវត្ថិភាព និងគ្មានសុវត្ថិភាព។

ការសម្ងាត់ដែលមានសុវត្ថិភាពគឺជាការសម្ងាត់ល្អដែលនាំមកនូវសុភមង្គល ឬភាពសប្បាយរីករាយដល់នរណាម្នាក់។ វាគឺជាព័ត៌មានដែលលក្ខណៈជាឯកជន ឬមិនត្រូវបានដឹងដោយអ្នកដទៃ ប៉ុន្តែទីបំផុតនឹងត្រូវបានបង្ហាញចេញ។ ឧទាហរណ៍: ការចង់ធ្វើឱ្យនរណាម្នាក់មានការភ្ញាក់ផ្អើលជាមួយកម្មពិធីជប់លៀងឬផ្តល់អំណោយដែលនឹងត្រូវបើកអោយឃើញក្នុងឱកាសពិសេស។

ការសម្ងាត់ដែលមិនមានសុវត្ថិភាព គឺមិនត្រូវបានគេដឹងថាវាជារឿងឯកជន ឬមិនត្រូវបានអ្នកដទៃដឹងទេ ហើយវាអាចធ្វើឱ្យនរណាម្នាក់មានអារម្មណ៍ថាមិនល្អ ឬមិនស្រួល។ ការសម្ងាត់ដែលគ្មានសុវត្ថិភាពអាចនាំមកនូវគ្រោះថ្នាក់ និងការឈឺចាប់ ឬធ្វើឱ្យនរណាម្នាក់ភ័យខ្លាចថានឹងមានរឿងអ្វីដែលអាក្រក់កើតឡើងចំពោះគេ។ ឧទាហរណ៍៖ អ្នកណាម្នាក់ធ្វើបាបអ្នក ឬឱ្យអ្នកធ្វើអ្វីមួយដែលអ្នកមានអារម្មណ៍ថាមិនមានសុវត្ថិភាព ឬមិនស្រួលហើយគេបានប្រាប់អ្នកថាឱ្យប្រាប់អ្នកដ៏ទៃឱ្យសោះបើមិនដូច្នេះទេអ្នកនឹងមានបញ្ហា។

សួរថា៖“ ហេតុអ្វីបានជាអ្នកណាម្នាក់ត្រូវការរក្សាការសម្ងាត់ ?”
គំរូចំលើយ៖ ប្រហែលអ្នករៀបចំពិធីជប់លៀងដ៏គួរអោយភ្ញាក់ផ្អើលមួយសម្រាប់មិត្តរបស់អ្នក។

ធ្វើ៖ រក្សាការសម្ងាត់ដោយសុវត្ថិភាពនិងការសម្ងាត់ដែលគ្មានសុវត្ថិភាព (សកម្មភាព ០៣ក)

ជំហានទី ០២

អន្តរកម្ម

▶ **និយាយ៖** អ្នកមានសិទ្ធិក្នុងការលុបចោលការសន្យាអំពីការសម្ងាត់ដែលគ្មានសុវត្ថិភាព ហើយអ្នកអាចប្រាប់នរណាម្នាក់ដែលអ្នកទុកចិត្ត។ ការសម្ងាត់ដែលមិនមានសុវត្ថិភាព ឬអាក្រក់អាចជាប់ទាក់ទងទៅនឹងអ្វីមួយដែលមានការឈឺចាប់ ឬគ្រោះថ្នាក់ដូចជាអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចជាដើម។ មនុស្សដែលមិនត្រូវ បានស្វាគមន៍ ឬមានកលល្បិចច្រើនតែងតែធ្វើឱ្យក្មេងៗសន្យាថានឹងរក្សារឿងអាក្រក់របស់ពួកគេជា “ ការសម្ងាត់ ” ។ មនុស្សដែលមិនគួរឲ្យទុកចិត្ត ឬមានកលល្បិចទាំងនេះក៏អាចត្រូវបានគេហៅថាជាអ្នកជួញដូរមនុស្សផងដែរ។ អំពើជួញដូរមនុស្សគឺជាទម្រង់នៃការកេងប្រវ័ញ្ចឬជាសកម្មភាពនៃការប្រើប្រាស់នរណាម្នាក់តាមរបៀបឃោរឃៅឬអយុត្តិធម៌។ ទម្រង់សំខាន់ៗនៃការជួញដូរមនុស្សរួមមាន ពលកម្មដោយបង្ខំ ពលកម្មដែលផ្សារភ្ជាប់ទៅនឹងការដោះបំណុល ការបង្ខំអោយសុំទាន និងការជួញដូរកុមារ។ អំពើជួញដូរមនុស្សកើតមានឡើងនៅគ្រប់ប្រទេសទាំងអស់ដែលប្រទេសនីមួយៗអាចជាឲ្យប្រទេសប្រភព(ជាប្រទេសដែលមនុស្សណាម្នាក់ត្រូវបានគេកេងប្រវ័ញ្ច និងបង្ខំឱ្យផ្លាស់ទៅទីតាំងផ្សេង) ប្រទេសដែលឆ្លងកាត់ (ជាប្រទេសដែលពួកគេត្រូវបានជួញដូរឆ្លងកាត់) និង/ឬជាប្រទេសគោលដៅ (ជាប្រទេសដែលពួកគេត្រូវបានគេជួញដូរទៅកាន់) ។ ទាសភាពបានកើតឡើងនៅគ្រប់ប្រទេស និងទ្វីបទាំងអស់តាំងតែពីរាប់ពាន់ឆ្នាំកន្លងមកហើយដោយមានកំណត់ត្រាដំបូងបំផុតនៅក្នុងប្រទេសចិនតាំងពីសតវត្សរ៍ទី១៦មុនគ្រិសករាជ។ ទាសភាពគឺជាផ្នែកមួយដ៏ធំនៃវប្បធម៌ជាច្រើននៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សលោកហើយនៅក្នុងអារ្យធម៌មួយចំនួនប្រជាជនភាគច្រើនគឺជាទាសករ ដែលមានចំនួនលើស "ប្រជាជនដែលមានសេរីភាព” ឬពលរដ្ឋ។

នគរ និងចក្រភពជាច្រើនត្រូវបានគេសាងសង់ឡើងដោយប្រើប្រាស់ទាសករ ឧទាហរណ៍ដូចជា៖ ប្រទេសក្រិក ប្រទេសរ៉ូម និងប្រទេសអេហ្ស៊ីបនាសម័យបុរាណ។ហូតមកដល់ពេលថ្មីៗនេះក្នុងរយៈពេល២០០ឆ្នាំចុងក្រោយនេះ ទាសភាពត្រូវបានគេចាត់ទុកថាវាគឺជារឿងធម្មតា និងមានការអនុវត្តដោយស្របច្បាប់។ អ្នកត្រូវបានអនុញ្ញាតឱ្យធ្វើជាកម្មសិទ្ធិរបស់អ្នកដទៃទៀតហើយមិនខ្វល់ថាគេបានប្រព្រឹត្តចំពោះយ៉ាងដូចម្តេចនោះទេ។ វាជារឿងដែលគួរឱ្យរន្ធត់នៅពេលយើងគិតអំពី រឿងនេះនៅពេលនេះ។ ទោះបីជាមេដឹកនាំពិភពលោកបានសំរេចថាឥឡូវនេះទាសភាពគឺជាអំពើខុសច្បាប់ក៏ដោយ ក៏មានមនុស្សជាច្រើនត្រូវបានគេជួញដូរកេងប្រវ័ញ្ច និងធ្វើជាទាសករនៅសព្វថ្ងៃនេះច្រើនជាងពេលណាៗទាំងអស់នៅក្នុងប្រវត្តិសាស្ត្រ។

ធ្វើ៖ ការស្វែងយល់អំពីការកេងប្រវ័ញ្ច (សកម្មភាព ០៣ខ)

▶ **និយាយ៖** ដំណឹងល្អគឺថាទោះបីការជួញដូរ និងកេងប្រវ័ញ្ចមនុស្សអាចជារឿងគួរឱ្យភ័យខ្លាចក៏ដោយក៏មានមនុស្សដ៏អស្ចារ្យ និងអង្គការជាច្រើននៅជុំវិញពិភពលោកបាននឹងកំពុងតស៊ូប្រយុទ្ធប្រឆាំងដើម្បីយុត្តិធម៌ និង ដើម្បីបញ្ចប់វា។ អំពើជួញដូរមនុស្សអាចត្រូវបានទប់ស្កាត់នៅពេលដែលអ្នកដឹងពីវិធីការពារខ្លួនអ្នកនិងអ្នកដទៃ។ ដូច្នេះវាជាការសំខាន់ណាស់ដែលត្រូវអ្នកត្រូវដឹងពីព្រំដែននៃសុវត្ថិភាពនិងគ្មានសុវត្ថិភាពផ្ទាល់ខ្លួន សិទ្ធិរបស់ខ្លួន សុវត្ថិភាពលើប្រព័ន្ធអនឡាន និងឯកជនភាពដែលការពារអ្នកកឲ្យក្លាយទៅជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

សួរថា៖ “ តើអ្នកគិតយ៉ាងដូចម្តេចចំពោះការកេងប្រវ័ញ្ចឬការជួញដូរមនុស្សនាពេលបច្ចុប្បន្ននេះ ? ”

គំរូចំលើយ៖ កុមារអាចផ្តល់គំនិតណាមួយ ឧទាហរណ៍៖ ត្រូវបានគេបង្ខំឱ្យធ្វើការច្រើនម៉ោងនៅក្នុងរោងចក្រ ការសម្អាតផ្ទះរបស់នរណាម្នាក់ហើយមិនត្រូវបានអនុញ្ញាតឱ្យចាកចេញ ឬបានដេកគ្រប់គ្រាន់ឡើយ។

▶ **និយាយ៖** កុមារមានសិទ្ធិទទួលនឹងការអប់រំ (ឧទាហរណ៍៖ ទៅសាលារៀន) មានសុខភាពល្អ មានពេលវេលាលេងជាមួយមិត្តភក្តិ និងមានការគ្រប់គ្រងលើរាងកាយរបស់ពួកគេដោយខ្លួនឯង (ឧទាហរណ៍៖ សិទ្ធិក្នុងការនិយាយថាទេចំពោះការប៉ះពាល់ដែលមិនស្រួល ឬគ្មានសុវត្ថិភាព) ។ សិទ្ធិទាំងនេះក៏ពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតផងដែរ (ឧទាហរណ៍៖ ហ្វេសប៊ុក, អ៊ីនស្តាហ្គ្រាម, ទីកតុក, ស្នែបឆាត, ឡាញ) និងវិធីដែលពួកគេអាចត្រូវគេបានរំលោភបំពាន (ឧទាហរណ៍៖ អ្វីដែលមនុស្សផ្សេងអាចសរសេរអំពីពួកគេ រូបភាពនៃរាងកាយរបស់ពួកគេ ការចែករំលែក និងអ្នកណាដែលជាមិត្តភក្តិនៅលើប្រព័ន្ធអ៊ីនធឺណិត)។ សូម្បីតែអ្វីៗដែលមាននៅលើអ៊ីនធឺណិតក៏អ្នកនៅតែមានសិទ្ធិដូចអ្វីដែល អ្នកធ្វើដោយផ្ទាល់ក្នុងនាមជាបុគ្គលហើយអ្នកក៏អាចនិយាយថា ទេ បានដែរ។

ធ្វើ៖ តើអ្នកនឹងធ្វើអ្វី ? (សកម្មភាព ០៣គ)

▶ **និយាយ៖** វាជាការសំខាន់ណាស់ប្រសិនបើយើងបានឃើញអ្វីមួយហើយយើងនិយាយវាចេញមកហើយធ្វើអ្វីមួយដើម្បីឆ្លើយតប។ សម្រាប់អ្នកដែលជាកុមារ អ្នកអាចនិយាយប្រាប់គ្រូឬឪពុកម្តាយរបស់អ្នក។ ទោះបីជាអ្នកនៅក្មេងក៏ដោយក៏សម្លេងរបស់អ្នកមានសារៈសំខាន់ដែរ !ប្រសិនបើអ្នកគិតថាមាននរណាម្នាក់កំពុងឈឺចាប់ឬមានគ្រោះថ្នាក់អ្វីមួយ នោះអ្នកមានសិទ្ធិក្នុងការនិយាយ។ យើងដឹងថាអ្នកមានសិទ្ធិដូចជាកុមារដែលចែងនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិកុមារ យូអិនស៊ីអស៊ី ៖ អ្នកមានសិទ្ធិទទួលបាននូវការការពារ (មាត្រា ៣) ហើយអ្នកមានសិទ្ធិទទួលបាននូវការស្តាប់ (មាត្រា ១២) ។

ជំហានទី ០៣

ការបំផុសគំនិត

▶ **និយាយ៖** យើងបានសិក្សាអំពីការជួញដូរ ការកេងប្រវ័ញ្ច និងវិធីដែលយើងអាចការពារខ្លួនយើងរួចហើយ។ ឥឡូវនេះ យើងអនុវត្តអ្វីដែលយើងបានរៀន ហើយបង្កើតវិធីដើម្បីជម្រុញទឹកចិត្តនិងអប់រំអ្នកដទៃ។

ធ្វើ៖ ការអំពាវនាវឱ្យធ្វើសកម្មភាព (សកម្មភាព ០៣ឃ)

សេចក្តីណែនាំអំពីសកម្មភាព

សកម្មភាព - វគ្គទី ០១

គុណតម្លៃនិងសិទ្ធិកុមារ

សកម្មភាព ១ ក

ការឱ្យតម្លៃទៅលើតម្លៃ

គោលបំណង

ដើម្បីបង្ហាញពីគុណតម្លៃខាងក្នុងរបស់មនុស្សគ្រប់រូប និងស្វែងយល់ពីទស្សនៈនៃគុណតម្លៃដែលកំណត់នូវបទដ្ឋាននៃអាកប្បកិរិយារបស់មនុស្សម្នាក់ៗនិងផ្តោតលើដំណើរការ។ ការនៃការកំណត់តម្លៃ។

សម្ភារ

កំណត់តម្លៃក្រដាស់ប្រាក់ (នៃតម្លៃណាមួយ) ពាក្យដែលសម្តែងពីគំនិតដែលគួរឱ្យទុកចិត្តនៅលើកាតសន្ទស្សន៍។

ជំហានទី ០១ បង្ហាញក្រដាស់ប្រាក់ដល់កុមារ។

សួរថា៖“ តើក្រដាសប្រាក់នេះមានតម្លៃប៉ុន្មាន ?” (រង់ចាំចម្លើយពីសិស្ស)។

ជំហានទី ០២ សូមបត់ក្រដាស់ប្រាក់ជាពាក់កណ្តាលហើយសួរទៅកាន់កុមារម្តងទៀត។

សួរថា៖“ ឥឡូវនេះវាមានតម្លៃប៉ុន្មាននៅពេលដែលខ្ញុំបត់វាពាក់កណ្តាល ? តើឥឡូវនេះ វាមានតម្លៃត្រឹមតែពាក់កណ្តាលមែនទេ ?” (រង់ចាំចម្លើយពីសិស្ស)។

ជំហានទី ០៣ បត់ក្រដាសប្រាក់ជាពាក់កណ្តាលចំនួនពីរទៅបីដងទៀតដោយធ្វើឱ្យវាកាន់តែតូចជាងមុន។សូមសួរកុមារនូវសំណួរដដែលៗបន្ទាប់ពីអ្នកបត់ក្រដាសប្រាក់នោះម្តងៗ។ ព្យាយាមបញ្ចុះបញ្ចូលកុមារថាក្រដាសប្រាក់នោះបានបាត់បង់តម្លៃរបស់វានៅរាល់ពេលដែលយើងបត់វាជាពាក់កណ្តាល។ សូមបន្តបត់ក្រដាស់ប្រាក់នោះឱ្យកាន់តែតូចរហូតដល់បត់បន្តទៀតលែងបានសូមលាវាឱ្យត្រឡប់ទៅរកទំហំធម្មតាវិញ។

▶ **និយាយ៖** មិនខ្វល់ថាខ្ញុំបានបត់ក្រដាសប្រាក់នេះប៉ុន្មានដងនោះទេ គឺក្រដាស់ប្រាក់នេះនៅតែរក្សាតម្លៃរបស់វាដូចមុនដដែល។ ខ្ញុំនៅតែអាចទិញរបស់មួយដែលស្មើរនឹងតម្លៃរបស់វាដដែលទោះបីជាវាត្រូវបានបត់ជាពាក់កណ្តាលក៏ដោយ។ ឥឡូវនេះស្រមៃថាក្រដាសប្រាក់នេះគឺជាមនុស្សម្នាក់ហើយរាល់ពេលដែលវាត្រូវបានបត់ជាពាក់កណ្តាលនោះមានន័យថាអ្នកនោះកំពុងតែជួបនូវបទពិសោធន៍ដែលលំបាកក្នុងជីវិតដោយសារតែមានអ្វីមួយដែលធ្វើឱ្យពួកគេមិនអាចគ្រប់គ្រងវាបាន។

សួរថា៖“ ប្រសិនបើអ្នកបានកើតនៅក្នុងប្រទេសផ្សេងតើតម្លៃជាមនុស្សរបស់អ្នកមានការផ្លាស់ប្តូរដែរឬទេ ?”

គំរូចំលើយ៖ ទេ! តម្លៃរបស់មនុស្សមិនអាចផ្លាស់ប្តូរដោយសារតែទីកន្លែងកំណើតរបស់ពួកគេនោះទេ។

សួរថា៖“ ប្រសិនបើអ្នកកើតមកមានពិការភាពតើតម្លៃជាមនុស្សរបស់អ្នកមានការផ្លាស់ប្តូរដែរឬទេ ?”

គំរូចំលើយ៖ ទេ! តម្លៃរបស់មនុស្សមិនអាចផ្លាស់ប្តូរដោយសារពួកគេមានពិការភាពនោះទេ។

សួរថា៖“ ប្រសិនបើអ្នកកើតមកក្នុងគ្រួសារក្រីក្រ ឬគ្រួសារអ្នកមាន តើតម្លៃជាមនុស្សរបស់អ្នកមានការផ្លាស់ប្តូរដែរឬទេ ?”

គំរូចំលើយ៖ ទេ! តម្លៃរបស់មនុស្សមិនអាចផ្លាស់ប្តូរដោយព្រោះពួកគេជាអ្នកមាន ឬអ្នកក្រនោះទេ។ តាមពិតមិនថាយើងកើតនៅទីកន្លែងណា សមាជិកគ្រួសារយើងជានរណាឬកាលៈទេសៈរបស់យើងបែបណានោះទេក៏តម្លៃជាមនុស្សរបស់យើងមិនផ្លាស់ប្តូរទេ។ យើងទាំងអស់គ្នាមានតម្លៃនិងសិទ្ធិមនុស្សដូចគ្នាៗ។ ដូចជាក្រដាស់ប្រាក់នេះអញ្ចឹងមិនថាខ្ញុំបត់វាប៉ុន្មានដងនោះទេក៏តម្លៃដើមរបស់វាមិនបានផ្លាស់ប្តូរដែរ។ ឥឡូវយើង ដឹងហើយថាយើងទាំងអស់គ្នាមានតម្លៃដូច្នេះយើងនឹងនិយាយអំពីអ្វីដែលយើងអោយតម្លៃម្តង។

សកម្មភាពទី ១ក - ការឱ្យតម្លៃទៅលើតម្លៃ

ជំហានទី ០៤ ដោយប្រើប័ណ្ណសន្ទស្សន៍ជាមួយពាក្យដែលសម្តែងពីគំនិតដែលគួរឱ្យទុកចិត្តរួចហើយសូមជ្រើសរើសកាតមួយដើម្បីបង្ហាញវាដល់មិត្តរួមថ្នាក់។ ពិភាក្សាពីតម្លៃដែលនៅលើកាតហើយកំណត់ថាតើវាតំណាងឱ្យអ្វីដែលជាការជឿទុកចិត្ត (គុណតម្លៃដែលល្អ) ឬអ្វីដែលវាមិនមែន (គុណតម្លៃមិនល្អ)។

ជំហានទី ០៥ សូមអានសេណារីយ៉ូខាងក្រោមទៅកាន់សិស្ស ហើយឱ្យពួកគេកំណត់ថាតើមនុស្សនៅក្នុងសេណារីយ៉ូនេះគួរឱ្យទុកចិត្តឬក៏ពួកគេជាមនុស្សដែលមានល្បិចកលដោយផ្អែកលើគុណតម្លៃដែលអ្នកទើបតែបានពិភាក្សានៅក្នុងថ្នាក់។

សេណារីយ៉ូទី ០១

ម៉ាក់របស់ចៃបានប្រាប់ឱ្យចៃទៅរើសតុក្កតាយកមកទុកមុនពេលឱ្យគាត់ចេញទៅលេងនៅខាងក្រៅ។ ផ្ទុយទៅវិញចៃបានយកតុក្កតានោះទៅលាក់នៅក្រោមគ្រែរបស់គាត់។ នៅពេលម្តាយរបស់គាត់សួរថា "តើកូនបានយកតុក្កតារបស់កូនយកមកទុក តាមអ្វីដែលម៉ាក់បានប្រាប់ដែរឬទេ ?" ចៃនិយាយថា "បាទ /ចាស"

សួរថា៖ "តើអ្នកគិតថាចៃជាមនុស្សគួរឲ្យទុកចិត្តបានឬទេ? ឬ គាត់ជាមនុស្សដែលមានកលល្បិច?"

គំរូចំលើយ៖ គាត់មិនគួរឱ្យទុកចិត្តទេ។ គាត់កំពុងប្រើកលល្បិចដោយនិយាយកុហកនិងបោកបញ្ឆោត។

សេណារីយ៉ូទី ០២

អាមីណា បានប្រាប់មិត្តរបស់នាងម្នាក់នូវអាថ៌កំបាំងមួយដែលថានាងនឹងឱ្យអំណោយដល់មិត្តរបស់ពួកគេនៅថ្ងៃខួបកំណើតរបស់នាង។ អាមីណា មិនបានប្រាប់នរណាម្នាក់ថាអំណោយនោះជាអ្វីទេព្រោះនាងចង់ឱ្យមានការភ្ញាក់ផ្អើល។

សួរថា៖ "តើនាងជាមនុស្សដែលគួរឱ្យទុកចិត្តឬជាមនុស្សដែលមានល្បិច?"

គំរូចំលើយ៖ នាងជាមនុស្សដែលគួរឱ្យទុកចិត្ត ហើយជាមនុស្សដែលមិត្តរបស់នាងអាចទុកចិត្តបានដោយនាងមានភាពស្មោះត្រង់ទៅនឹងការរក្សាការសម្ងាត់។

សេណារីយ៉ូទី ០៣

អ៊ីសាបេឡា គឺជាប្រធានក្រុមហើយតែងតែជ្រើសរើសយក យ៉ារេឌ ធ្វើជាអ្នកលេងដ៏សំខាន់ដោយដឹងថាវាមានភាពអយុត្តិធម៌ចំពោះកីឡាករដទៃ ទៀតដែលមិនបានចូលលេង។ អ៊ីសាបេឡា ដឹងថាយ៉ារេឌបានបន្លំនៅពេលគាត់លេង នេះដោយជាមូលហេតុដែលនាងតែងតែជ្រើសរើសគាត់។ នាងធ្វើអ្វីគ្រប់យ៉ាងឱ្យតែបានឈ្នះការប្រកួតនេះ។

សួរថា៖ " តើនាងជាមនុស្សគួរឱ្យទុកចិត្តឬមានល្បិចកល ? "

គំរូចំលើយ៖ នាងកំពុងល្បិចកលតាមរយៈការកេងប្រវ័ញ្ចលើការលេងដោយអយុត្តិធម៌ និងទាញយកផលប្រយោជន៍ពីយ៉ារេឌ។

សេរណារីយ៉ូទី ០៤

ម៉ី មិនបានរៀនត្រៀមសម្រាប់ការធ្វើតេស្តរបស់នាងទេ ដូច្នេះនាងបានសុំមិត្តរបស់នាងឱ្យជួយប្រាប់ចម្លើយដើម្បីឱ្យនាងបានជាប់ការធ្វើតេស្ត។

សួរថា៖ " តើនាងជាមនុស្សគួរឱ្យទុកចិត្តឬមានកលល្បិច ? "

គំរូចំលើយ៖ នាងជាមនុស្សមិនស្មោះត្រង់ដោយព្រោះនាងបានបន្លំឬលួចមើលចម្លើយក្នុងពេលប្រលង។

សេណារីយ៉ូទី ០៥

មីត មើលឃើញថា ឡេតសា បានជ្រុះលុយខ្លះចេញពីហោប៉ៅរបស់នាងដោយមិនដឹងខ្លួន មីតក៏បានរើសលុយនោះហើយប្រគល់វាឱ្យទៅ ឡេតសា វិញ។

សួរថា៖ " តើគាត់កំពុងបង្ហាញលក្ខណៈនៃភាពគួរឱ្យទុកចិត្តឬល្បិចកល ? "

គំរូចំលើយ៖ គាត់គួរឱ្យទុកចិត្តដោយគាត់បានបង្ហាញនូវភាពស្មោះត្រង់ និង សុចរិតភាពរបស់នាង។

ភាពស្មោះត្រង់

ការកុហក់

សេចក្តីពិត

ការបោកបញ្ឆោត

ស្មោះត្រង់

ការបោកប្រាស់

សុច្ចរិតភាព

ការកេងបន្លំ

ដែលអាចពន្យល់បាន

ការទាញយកអត្ថប្រយោជន៍
ពីនរណាម្នាក់

ភក្តីភាព

ក្លែងក្លាយ
ឬកុហកបោកប្រាស់

សកម្មភាព ០១៩

កម្រងសិទ្ធិទាំងបួនរបស់កុមារ

គោលបំណង

ដើម្បីស្វែងយល់អំពីសិទ្ធិសំខាន់ៗទាំងបួនរបស់កុមារដែលមានចែង នៅក្នុងអនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។

គោលបំណង

ប្រភេទចំណាត់ថ្នាក់នៃសិទ្ធិរបស់កុមារ (កាត់ទាំង០៤ចេញ) កាតសិទ្ធិរបស់កុមារ (កាត់ទាំង១២ចេញ)

ជំហានទី ០១ ដាក់ស្លាកសញ្ញានៅជ្រុងនៃបន្ទប់នីមួយៗជាមួយសិទ្ធិមួយក្នុងចំណោមប្រភេទនៃសិទ្ធិទាំងបួនរបស់កុមារ (ការអភិវឌ្ឍរស់រានមានជីវិត ការចូលរួម និងការការពារ) ។

ជំហានទី ០១ ជ្រើសរើសយកប័ណ្ណសិទ្ធិកុមារហើយអានជាឧទាហរណ៍ដល់សិស្ស។ ប្រាប់ឱ្យកុមារបន្តទៅកាន់ជ្រុងម្ខាងទៀតនៃបន្ទប់ដែលពួកគេជឿថាវាតំណាងឱ្យប្រភេទសិទ្ធិដែលសមស្របសម្រាប់និងជាក់លាក់។ សកម្មភាពនេះអាចត្រូវបានលេងជាលក្ខណៈហ្គេមមួយដែលកុមារត្រូវផ្លាស់ទីពីជ្រុងមួយទៅជ្រុងមួយទៀតដែលពួកគេគិតថាត្រឹមត្រូវ។ (ជំរើស៖ កុមារដែលទៅជ្រុងខាងស្តាំនឹងទទួលបានឱកាសក្នុងការលេងបន្តហើយនៅតែបន្តនៅក្នុងក្រុមដដែល) ។

ជំហានទី ០៣ ពិភាក្សាឱ្យស្គាល់អំពីប័ណ្ណនៃសិទ្ធិនីមួយៗរបស់កុមារ ព្រោះសន្លឹកបណ្ណ័នោះនឹងត្រូវបានជ្រើសរើសតាមរយៈការលេងហ្គេម។សួរកុមារថាតើចំណាត់ថ្នាក់មួយណាដែលពួកគេជឿថាវាសមស្របបំផុតទៅនឹងសិទ្ធិដែលពួកគេបានឮ ហើយត្រូវអោយពួកគេបង្ហាញពីហេតុផលដែល ពួកគេជ្រើសរើសទៅឈរនៅទីជ្រុងនោះ។

ប្រភេទនៃសិទ្ធរបស់កុមារ	
សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានខ្យល់អាកាសបរិសុទ្ធ ស្អាតទឹក និងអាហារដែលមានជីវជាតិគ្រប់គ្រាន់	**សិទ្ធិទទួលបានការការពារ** គ្មានការសម្លុត ឬសុវត្ថិភាពពីការចាប់ពង្រត់ឬលក់ និងគ្មានគ្រោះថ្នាក់ពីការកេងប្រវ័ញ្ច
សិទ្ធិក្នុងការចូលរួម សិទ្ធិក្នុងការចែករំលែកយោបល់ចូលរួមជាមួយសាសនា និងសេរីភាពបញ្ចេញមតិ	**សិទ្ធិក្នុងការអភិវឌ្ឍន៍** ការអប់រំ ការលេង និងសកម្មហើយនឹងការសម្រាក

សកម្មភាព ១២ - កម្រងសិទ្ធទាំងបួនរបស់កុមារ (បន្ត)

ជំហានទី ០៤ សង្ខេបពីសកម្មភាពជាមួយសំណួរពិភាក្សាខាងក្រោមៈ

សួរថាៈ“ តើអ្នកគិតថាកុមារអាចទទួលរងគ្រោះថ្នាក់យ៉ាងដូចម្តេចខ្លះប្រសិនបើសិទ្ធិទាំងនេះមិនត្រូវបានការពារ ?”

គំរូចំលើយៈ ប្រសិនបើសិទ្ធិរបស់ពួកគេមិនទទួលបាននូវការការពារនោះ ខ្យល់អាកាស ទឹក និងអាហារដែលពួកគេទទួលបានអាចកខ្វក់ នឹងធ្វើឱ្យកុមារឈឺ។ និងបណ្តាលឱ្យអ្នកផ្សេងសម្លុត ហើយបង្កើតឱ្យមានការភ័យខ្លាច និងកង្វះទំនុកចិត្តលើខ្លួនឯង។

សួរថាៈ“ នរណាជាអ្នកទទួលខុសត្រូវដើម្បីធានាថាសិទ្ធិរបស់កុមារទាំងនេះត្រូវបានការពារ ?”

គំរូចំលើយៈ អ្នកដឹកនាំក្នុងតំបន់ និងថ្នាក់ជាតិ ឪពុកម្តាយ និងកុមារដទៃទៀតក៏មានទំនួលខុសត្រូវក្នុងការជួយការពារកុមារ និងសិទ្ធិរបស់ពួកគេ។

សួរថាៈ“ តើការសម្រេចចិត្តប្រកបដោយភាពឆ្លាតវៃអាចការពារកុមារពីគ្រោះថ្នាក់ដោយរបៀបណា ?”

គំរូចំលើយៈ ធ្វើការដោយឆ្លាតវៃការពារកុមារពីគ្រោះថ្នាក់នៅពេលពួកគេរៀនជ្រើសរើសអាហារដែលមានសុខភាពល្អដើម្បីបរិភោគ សុំទឹកស្អាតញាំ និងមានប្រាជ្ញានៅពេលពួកគេឃើញអ្វីមួយនោះពួកគេនឹងនិយាយវាចេញមក។



សិទ្ធិទទួលបានការការពារ



សិទ្ធិក្នុងការអភិវឌ្ឍ



សិទ្ធិរស់រានមានជីវិត

សិទ្ធិក្នុងការចូលរួម



សិទ្ធិទទួលបានខ្យល់អាកាសបរិសុទ្ធ

សិទ្ធិទទួលបានទឹកស្អាត



សិទ្ធិទទួលបានអាហារដែលមានជីវជាតិ
គ្រប់គ្រាន់

សិទ្ធិមិនត្រូវបានសម្លុត ឬគំរាមកំហែង

សិទ្ធិទទួលបានសុវត្ថិភាពពីការ
ចាប់ពង្រត់ ឬការលក់ដូរ

សិទ្ធិរួចផុតពីការកេងប្រវ័ញ្ច

សិទ្ធិក្នុងការបញ្ចេញមតិលើបញ្ហានានា



សិទ្ធិចូលរួមជាមួយសាសនា

សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ

សិទ្ធិទទួលបានការលេងលំហែ និងសកម្ម

សិទ្ធិទទួលបានការសម្រាក

សិទ្ធិទទួលបានការអប់រំ

មេរៀន ០១

សកម្មភាព ១គ

សមភាព និង សមធម៌

គោលបំណង

ដើម្បីស្វែងយល់អំពីគោលគំនិតនៃពាក្យថា សមភាព និង សមធម៌ដើម្បីយល់ដឹងអំពីការរើសអើង ការកេងប្រវ័ញ្ច និងយុត្តិធម៌ ។

សម្ភារៈត្រូវការ៖

កាតរូបភាពស្តីអំពីសមភាព និងសមធម៌

ជំហានទី១៖ បង្ហាញរូបភាពដំបូងនៃសមភាពនិងសមធម៌

សួរថា៖ "តើអ្នកសង្កេតឃើញអ្វីខ្លះនៅក្នុងរូបភាពដំបូងនេះ?"

ចម្លើយគម្រូ៖ សមភាព គឺកុមារគ្រប់រូបទទួលបានប្រអប់ទំហំប៉ុនៗគ្នា ដូចៗគ្នាទោះបីជាពួកគេ ម្នាក់ៗមានកំពស់ខុសៗគ្នាក៏ដោយ ។

សួរថា៖ "តើអ្នកគិតថា ក្មេងៗក្នុងរូបភាពនេះយល់ថាការផ្តល់ទំហំប្រអប់នេះគឺយុត្តិធម៌ដែរឬទេ? តើមានអ្វីខ្លះដែលអយុត្តិធម៌ពាក់ព័ន្ធនឹងរូបភាពនេះ?

ចម្លើយគម្រូ៖ បីផ្តល់ជូនប្រអប់មានទំហំស្មើគ្នា មិនមានន័យថាលទ្ធផលចេញមកស្មើគ្នានោះទេ ។ ពេលខ្លះបុគ្គលមួយចំនួនត្រូវការជំនួយច្រើនជាងបុគ្គលដទៃទៀតដើម្បីអាចសម្រេចបានគោលដៅដូចគ្នា ។

សួរថា៖ "តើអ្វីខ្លះដែលអាចធ្វើបានដើម្បីឲ្យស្ថានភាពនេះកាន់តែមានយុត្តិធម៌?"

ចម្លើយគម្រូ៖ សមធម៌ ។ ផ្តល់ជូនប្រអប់ខ្ពស់ជាងនេះឬបន្ថែមចំនួនប្រអប់ដល់កុមារដែលមានកម្ពស់ទាបសម្រាប់ឲ្យគាត់ឈរ ដូច្នេះគាត់អាចឈោងចាប់សិទ្ធិរបស់គាត់បាន ។

ជំហានទី២៖ សុំឲ្យសិស្សពិភាក្សាគ្នាអំពី លទ្ធផលបែបណាដែលអាចនឹងកើតឡើង ប្រសិនបើស្ថានភាពនេះមិនត្រូវបានផ្លាស់ប្តូរ ។

ចម្លើយគម្រូ៖ លទ្ធផលគឺបញ្ហាគម្លាតនៅតែបន្តកើតមានដដែល ដូច្នេះកុមារមិនអាចឈោងចាប់សិទ្ធិឬទទួលបានយុត្តិធម៌សម្រាប់សិទ្ធិរស់នៅដែលស្មើភាពគ្នានោះទេ ។

ជំហានទី៣៖ ជ្រើសរើសដំណោះស្រាយមួយដែលសុវត្ថិភាពនិងប្រកដោយការគោរព ។ យើងអាចមានមធ្យោបាយផ្សេងដែលអាចធ្វើបានដើម្បីឈានទៅរកដំណោះស្រាយមួយដែលមានសមធម៌ និងផ្តល់ជូនយុត្តិធម៌សម្រាប់ទាំងអស់គ្នា ។ បង្ហាញសិស្សនូវរូបភាពសមធម៌ ដែលការគាំទ្រត្រូវបានអនុញ្ញាតឲ្យផ្តល់ជូនទៅតាមតម្រូវការចាំបាច់ដើម្បីឲ្យបុគ្គលគ្រប់រូបអាចទទួលបាននូវសិទ្ធិរស់រានដោយស្មើភាពគ្នា ។


សិទ្ធិមនុស្ស
OPPORTUNITY
សមធម៌


សិទ្ធិមនុស្ស
OPPORTUNITY
សមភាព

សកម្មភាព ០១ឃ

ការអំពាវនាវឱ្យធ្វើសកម្មភាព

ឱ្យសិស្សឆ្លុះបញ្ចាំងពីសារៈសំខាន់នៃសិទ្ធិរបស់កុមារដោយប្រើវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រខាងក្រោម។ អញ្ជើញពួកគេឱ្យបង្ហាញពីរបៀបដែលសិទ្ធិទាំងនេះរួមចំណែកធ្វើឱ្យពិភពលោកមួយដែលកុមារគ្រប់រូបរស់នៅប្រកបដោយសេរីភាព។ សម្រាប់បញ្ហាប្រឈមបន្ថែមទៀតសូមឱ្យកុមារគិតអំពីពិភពលោកមួយដែលគ្មានការគោរពសិទ្ធិមនុស្ស និងគ្មានច្បាប់។ សួរពួកគេថាតើពួកគេគិតថាវាជារឿងល្អ ឬអាក្រក់? ហេតុអ្វី? សូមអញ្ជើញពួកគេឱ្យពន្យល់បន្ថែមទៀតដោយប្រើវិធីសាស្ត្រដែលពួកគេបានជ្រើសរើស។

បង្កើតវា (សិល្បៈ)

ឱ្យសិស្សគូររូប ឬផាត់ពណ៌លើរូបភាពដែលតំណាងឱ្យសិទ្ធិរបស់កុមារ ឬអំពីអត្ថន័យនៃសិទ្ធិទាំងនោះចំពោះពួកគេ។ សិស្សក៏អាចធ្វើការជាមួយគ្នាដើម្បីបង្កើតផ្ទាំងរូបភាព ផូស្ទ័ ឬ ផ្ទាំងផ្សព្វផ្សាយពានិជ្ជកម្ម។

សម្ភារ: ប៊ិច ខ្មៅដៃ ថ្នាំលាប ក្រដាស ស្ទីគ័រ ឬ វត្ថុផ្សេងៗដែលអាចរកបាន

ធ្វើសកម្មភាពអំពីវា (ការសម្តែង)

ឱ្យសិស្សធ្វើការជាក្រុមដើម្បីបង្កើតការសំដែង ឬល្ខោនដែលផ្អែកលើការការពារសិទ្ធិរបស់កុមារ។ ពួកគេនឹងសរសេរខ្លីៗអំពីរឿងដែលត្រូវសម្តែងនោះ ហើយជ្រើសរើសតួអង្គនីមួយៗចេញពីសមាជិកក្នុងក្រុមរបស់ពួកគេ។

សម្ភារ: ប៊ិច ខ្មៅដៃ ក្រដាស ការស្លៀកពាក់

ការសរសេរវា (និក្ខេបបទ)

សិស្សនឹងបង្ហាញនូវអ្វីដែល "ជាពិភពលោកមួយប្រកបដោយសន្តិភាពឬសហគមន៍ដ៏ល្អឥតខ្ចោះរបស់ពួកគេ" ជាទីកន្លែងដែលកុមារគ្រប់រូបមានសិទ្ធិសេរីភាព ដោយការសរសេរ ឬការគូរនិងគំនិតច្នៃប្រឌិតរបស់ពួកគេ។ ឱ្យពួកគេធ្វើការវិភាគទៅលើសិទ្ធិជាក់លាក់ទៅចំពោះ"សហគមន៍ដ៏ល្អឥតខ្ចោះ" របស់ពួកគេហើយពីអ្វីដែលនឹងកើតឡើងប្រសិនបើសិទ្ធិរបស់ពួកគេទាំងនោះត្រូវបានរំលោភបំពាន។

សម្ភារ: ប៊ិច ខ្មៅដៃ ក្រដាស

ប្រាប់អំពីវា (តន្ត្រី)

ឱ្យសិស្សធ្វើការជាក្រុមដើម្បីបង្កើតចម្រៀង រ៉េប ឬកំណាព្យដើម្បីបង្ហាញពីអារម្មណ៍របស់ពួកគេចំពោះសិទ្ធិរបស់ពួកគេក្នុងនាមជាកុមារ ឬពន្យល់ពីសិទ្ធិរបស់កុមារ និងចែករំលែកពីមូលហេតុដែលពួកគេជ្រើសរើសសិទ្ធិពិសេសទាំងនោះក្នុងការបកស្រាយតាមរយៈចម្រៀងរបស់ពួកគេ។

សម្ភារ: ប៊ិច ខ្មៅដៃ ក្រដាស និង ឧបករណ៍ភ្លេង

សកម្មភាព - វគ្គទី ០១

គុណតម្លៃ និងសិទ្ធិកុមារ

ផ្នែក ០២

សកម្មភាព ០២ក

ប្រភេទនៃការធ្វើចំណាកស្រុក

គោលបំណង

ដើម្បីកំណត់ និងពន្យល់អំពីប្រភេទនៃការធ្វើចំណាកស្រុកទាំងបួនប្រភេទគឺៈ ចំណាកស្រុកក្នុងស្រុក ចំណាកស្រុកក្រៅស្រុក ចំណាកស្រុកតាមរដូវកាល និងអន្តោប្រវេសន៍។

គោលបំណង

រូបភាពចំណាកស្រុកជម្រើស “ប្រអប់” សកម្មភាព ប្រអប់ៈ បាល់ ទឹកមួយកែវ

ជំហានទី ០១ ណែនាំអំពីការធ្វើចំណាកស្រុកទាំង០៤ ប្រភេទដោយសួរថាហេតុអ្វីបានជាប្រជាជនធ្វើការផ្លាស់ទីលំនៅ? តើចលនានៃការផ្លាស់ទីរបស់មនុស្សមានប៉ុន្មានប្រភេទ? បន្ទាប់មកបង្ហាញរូបភាពមួយក្នុងចំណោមរូបភាពខាងក្រោមដើម្បីបង្ហាញពីប្រភេទនៃការធ្វើចំណាកស្រុកមួយក្នុងចំណោមប្រភេទនៃការធ្វើចំណាកស្រុកទាំង០៤ (ឬប្រើ ជម្រើស “ ប្រអប់” សកម្មភាព) ។ សូមឱ្យសិស្សបកស្រាយអំពីរូបភាពតំណាងនីមួយៗ។

សកម្មភាព ២ ក - ប្រភេទនៃនៃការធ្វើចំណាកស្រុក (បន្ត)

ប្រភេទនៃការធ្វើចំណាកស្រុក	
ការធ្វើចំណាកស្រុកក្នុងស្រុក គឺជាចលនានៃការផ្លាស់ប្តូរនៅក្នុងរដ្ឋ ឬប្រទេសមួយ	**ចំណាកស្រុកក្រៅស្រុក** គឺជាចលនានៃការផ្លាស់ប្តូរទៅកាន់ រដ្ឋ ប្រទេស ឬទ្វីបផ្សេងៗគ្នា
ការធ្វើចំណាកស្រុកតាមរដូវកាល គឺជាការផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយក្នុងគោលបំណងធ្វើកសិកម្ម ការប្រមូលផល ឬដោយសារការប្រែប្រួលអាកាសធាតុ។	**អន្តោប្រវេសន៍** អន្តោប្រវេសន៍គឺជាការផ្លាស់ប្តូរទីលំនៅពីប្រទេសមួយទៅតាំងទៅលំនៅនៅប្រទេសថ្មីមួយទៀតជាអចិន្ត្រៃយ៍

ជំរើស៖“ ប្រអប់” សកម្មភាព

ប្រើប្រអប់ទទេចំនួនពីរនិងកូនបាល់ពីរ ឬបី។ ប្តូរទីតាំងបាល់នៅចន្លោះប្រអប់ដើម្បីបង្ហាញពីគំនិតនៃការធ្វើចំណាកស្រុក និងប្រភេទផ្សេងៗនៃការធ្វើចំណាកស្រុក៖

- **ការធ្វើចំណាកស្រុកក្រៅស្រុក** - ផ្លាស់ទីបាល់មួយចេញពីប្រអប់មួយទៅប្រអប់មួយទៀត។
- **ការធ្វើចំណាកស្រុកក្នុងស្រុក** - រំកិលទីតាំងរបស់បាល់នៅខាងក្នុងប្រអប់។
- **ការធ្វើចំណាកស្រុកតាមរដូវកាល** - ចាក់ទឹកចូលក្នុងប្រអប់មួយហើយផ្លាស់ទីរបស់បាល់ទៅកាន់ប្រអប់មួយផ្សេងទៀត។
- **អន្តោប្រវេសន៍** - រំកិលទីតាំងរបស់បាល់ពីប្រអប់មួយទៅប្រអប់មួយទៀតហើយបន្ទាប់មកសរសេរពាក្យថា “ពលរដ្ឋ” នៅលើ ក្រដាសនោះហើយដាក់វាចូលទៅក្នុងប្រអប់។

សកម្មភាព ០២ខ

ការធ្វើចំណាកស្រុកដែលមានសុវត្ថិភាព ឬគ្មានសុវត្ថិភាព?

សកម្មភាព ០២ខ

ដើម្បីពិនិត្យមើលឡើងវិញនូវសេណារីយ៉ូដែលអាចកើតមានដើម្បីកំណត់ការធ្វើចំណាកស្រុកដែលមានសុវត្ថិភាពឬគ្មានសុវត្ថិភាព និងដើម្បីពិភាក្សានៅក្នុងថ្នាក់ពីរបៀបដែលធ្វើចំណាកស្រុកប្រដបដោយសុវត្ថិភាព។

សម្ភារៈ សេណារីយ៉ូនៃការធ្វើចំណាកស្រុក, កាតសុវត្ថិភាពនិងមិនមានសុវត្ថិភាព (មួយឈុតសម្រាប់សិស្សម្នាក់)

ជំហានទី ០១ ចែកប័ណ្ណ“ សុវត្ថិភាព” និង“ គ្មានសុវត្ថិភាព” ដល់សិស្សម្នាក់ៗ។

ជំហានទី ០២ សូមអានសេណារីយ៉ូខាងក្រោមអោយសិស្សស្តាប់។ សុំឱ្យពួកគេលើកកាតដែលពួកគេជឿថាត្រឹមត្រូវចំពោះសេណារីយ៉ូ(សុវត្ថិភាពឬមិនមានសុវត្ថិភាព)។ នៅពេលដែលសិស្សទាំងអស់បានលើកកាតរបស់ពួកគេហើយសូមចែករំលែកចម្លើយដែលត្រឹមត្រូវជាមួយពួកគេ និងសូមចំណាយពេលខ្លះដើម្បីពន្យល់ពីមូលហេតុដែលសេណារីយ៉ូនេះដែលមានសុវត្ថិភាព ឬគ្មានសុវត្ថិភាព។

សេណារីយ៉ូទី ០១

ឪពុករបស់សារ៉ាមានការងារថ្មីដូច្នេះឥឡូវនេះសារ៉ា និងក្រុមគ្រួសាររបស់នាងកំពុងផ្លាស់ទៅរស់នៅទីក្រុងឡុង។ ពួកគេបានទៅស្ថានទូតហើយដាក់ពាក្យស្នើសុំទិដ្ឋាការ។

សុវត្ថិភាព | ពួកគេបានអនុវត្តតាមនីតិវិធីច្បាប់ហើយបានដាក់ពាក្យស្នើសុំទិដ្ឋាការ។

សេណារីយ៉ូទី ០២

អ៊ីសាបេឡា បានក្រោកពីព្រលឹមជាមួយឪពុកម្តាយរបស់នាងហើយក៏បាននាំគ្នាដើរទៅកាន់ព្រំដែន។ មានផ្លូវពិសេសដែលពួកគេដើរទៅដោយគ្មាននរណាម្នាក់បានឃើញពួកគេឆ្លងកាត់ព្រំដែនឡើយ។ ពួកគេស្នាក់នៅទីនោះដើម្បីថ្ងៃធ្វើការហើយបន្ទាប់មកត្រឡប់មកវិញ។

មិនមានសុវត្ថិភាព | ពួកគេបានដើរតាមផ្លូវមួយដែលប្រហែលជាផ្លូវដែលមិនស្របច្បាប់ ឬមិនមានសុវត្ថិភាព។ ពួកគេមិនចង់ឱ្យគេចាប់បានទេ។

សេណារីយ៉ូទី ០៣

អ្នកជិតខាងរបស់ ម៉ាយ៉ា បានរត់មករកផ្ទះរបស់ពួកគេហើយស្រែកថា "យើងត្រូវចាកចេញទៅហើយ។ ពួកគេមកដល់ហើយ!" ម្តាយរបស់ម៉ាយ៉ាចាប់ផ្តើមដាក់សម្លៀកបំពាក់នៅក្នុងការកាបូប ហើយឪពុករបស់នាងចាប់យកកាបូបដាក់លុយរបស់គាត់។ ពួកគេរត់ចេញពីផ្ទះយ៉ាងលឿនដែលធ្វើឱ្យ ម៉ាយ៉ា មិនមានពេលដើម្បីយកសៀវភៅដែលនាងចូលចិត្តអានទៅជាមួយបានទេ។ អ្នកជិតខាងរបស់ពួកគេស្គាល់បុរស ម្នាក់ដែលអាចឱ្យពួកគេជិះទូកជាមួយដើម្បីរត់គេចខ្លួន។

មិនមានសុវត្ថិភាព | ពួកគេត្រូវចាកចេញយ៉ាងលឿនហើយពួកគេបានជឿទុកចិត្តលើជនចម្លែកម្នាក់ដូច្នេះអាចធ្វើឱ្យពួកគេមិនមានសុវត្ថិភាព។

សេណារីយ៉ូទី ០៤

យ៉ារេឌ ត្រូវបានគេផ្តល់ការងារដ៏ល្អមួយនៅទីក្រុងបាងកក។ដោយសារតែគាត់មិនមែនជាជនជាតិថៃ គាត់ត្រូវបានគេតម្រូវឱ្យមានប័ណ្ណការងារ និងទិដ្ឋាការប៉ុន្តែវាថ្លៃណាស់សម្រាប់គាត់ក្នុងការធ្វើវា។ បងប្អូនជីដូនមួយរបស់ យ៉ារេឌ ស្គាល់ទីកន្លែងដែលគាត់អាចទទួលឯកសារទាំងនោះដូច្នេះ ពួកគេអាចរំលងនីតិវិធី ឬតាមវិធី មិនស្របច្បាប់ហើយពួកគេអាចចំណាយប្រាក់តិចតួចប៉ុណ្ណោះ។

មិនមានសុវត្ថិភាព | គាត់ទំនងជាប្រើឯកសារក្លែងក្លាយដែលមិនមានសុវត្ថិភាព។

សេណារីយ៉ូទី ០៥

អាមីណា កំពុងរៀបចំវិស្សមកាលរបស់នាងទៅកាន់ប្រទេសអូស្ត្រាលី។ នាងស្វែងរកមើលពត៌មានដែលនាងត្រូវការតាមប្រព័ន្ធអនឡាញមុនពេលនាងធ្វើដំណើរទៅ។

មានសុវត្ថិភាព | នាងបានស្រាវជ្រាវ និងរៀបចំមុនពេលដែលនាងធ្វើដំណើរទៅដូច្នេះនាងអាចមានសុវត្ថិភាព។

សេណារីយ៉ូទី ០៦

ម៉ារីអូ បានធ្វើដំណើរជាមួយគ្រួសាររបស់គាត់ពីរទៅបីសប្តាហ៍ហើយ។ ពួកគេកំពុងធ្វើដំណើរទៅផ្ទះពូរបស់គាត់នៅទីក្រុងបូស្តុន ជាទីកន្លែងដែលនឹងមានសុវត្ថិភាពជាងមុន។ ម្តាយរបស់ ម៉ារីអូ បានបំពេញក្រដាសស្នាមហើយនិយាយជាមួយអង្គការមួយដែលអាចទុកចិត្តបានដែលសន្យាថានឹងជួយពួកគេក្នុងការរៀបចំទិដ្ឋាការរបស់ពួកគេ។

មានសុវត្ថិភាព | គាត់បានទទួលជំនួយពីអង្គការដែលអាចទុកចិត្តបានដោយប្រើដំណើរការនៃការបំពេញឯកសាររបស់គាត់ជាផ្លូវការ។

ជំហានទី០៣ ការពិភាក្សានៅក្នុងថ្នាក់

- **និយាយ៖** សេណារីយ៉ូទាំងនេះគឺជាស្ថានភាពនៃជីវិតពិតរបស់មនុស្សជាច្រើន។ នៅពេលដែលយើងក្រឡេកមើលពីសេណារីយ៉ូទាំងនេះជាមួយគ្នាគឺវាមានភាពងាយស្រួលក្នុងការជួយឱ្យយើងមើលឃើញនូវអ្វីដែលនឹងត្រូវកើតឡើង និងពីវិធីដែលយើងអាចធ្វើការសម្រេចចិត្តប្រកបដោយភាពឆ្លាតវៃដើម្បីជួយលើកកម្ពស់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។

សួរថា៖“ តើមាននរណាម្នាក់អាចកំណត់នូវភាពខុសគ្នារវាងវិធីដែលធ្វើចំណាកស្រុកដោយ "សុវត្ថិភាព" និង “គ្មានសុវត្ថិភាព” ដែរឬទេ? តើអ្នកគិតថាមានសេណារីយ៉ូអ្វីដែលធ្វើឱ្យការធ្វើចំណាកស្រុកកាន់តែមានសុវត្ថិភាពជាងមុន?”

> គំរូចំលើយ៖ ប្រសិនបើយើងដាក់ពាក្យស្នើសុំទិដ្ឋាការ ហើយយើងមានលិខិតឆ្លងដែន ហើយយើងបានធ្វើដំណើរជាមួយក្រុមមនុស្សដែលគួរទុកចិត្តបាន នេះហើយគឺជាមធ្យោបាយដែលជួយឱ្យយើងធ្វើចំណាកស្រុកកាន់តែមានសុវត្ថិភាពជាងមុន។ ប្រសិនបើយើងព្យាយាមធ្វើចំណាកស្រុកដោយខ្លួនឯង ឬអនុញ្ញាតឱ្យមនុស្សដែលមានកលល្បិចកជួយយើងក្នុងការធ្វើចំណាកស្រុកដោយគ្មានឯកសារត្រឹមត្រូវនោះយើងកំពុងដាក់ខ្លួនឯងឱ្យស្ថិតនៅក្នុងស្ថានភាពដែលគ្មានសុវត្ថិភាព ។

សុវត្ថិភាព

មិនមានសុវត្ថិភាព

ផ្នែក ០២

សកម្មភាពទី ០២គ

ល្បែងចំណាកស្រុក

គាលបំណង

ដើម្បីណែនាំ និងអនុវត្តគោលគំនិតសំខាន់ៗនៃការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងមិនមានសុវត្ថិភាព។ ដោយធ្វើការសហការគ្នាដើម្បីធ្វើឱ្យការធ្វើចំណាកស្រុកឆ្លងកាត់ទន្លេសិប្បនិមិត្តបានជោគជ័យ។

គោលបំណង

ក្រដាសកាសែត កៅអី ឬខ្សែពួរ សម្រាប់សម្គាល់មាត់ទន្លេ។

ជំហានទី ០១ សរសេរពាក្យខាងក្រោមនៅលើក្រដាស (មួយពាក្យក្នុងមួយសន្លឹក)។

ការធ្វើចំណាកស្រុកដោយសុវត្ថិភាព	ចំណាកស្រុកដែលគ្មានសុវត្ថិភាព
វីសា ឬទិដ្ឋាការ លិខិតឆ្លងដែន លុយ គ្រួសារ សុវត្ថិភាព ទំនុកចិត្ត ច្បាប់	គ្មានទិដ្ឋាការ គ្មានលុយ គ្មានការគាំទ្រ គ្មានលិខិតឆ្លងដែន

ជំហានទី ០២ បង្កើតទឹកទន្លេសិប្បនិមិត្តមួយដោយប្រើកៅអី រឺខ្សែពួរដើម្បីកំណត់សំគាល់ពីតំបន់មាត់ទន្លេ។បន្ទាប់មកយកក្រដាសទាំងប្រាំពីរសន្លឹកដែលមានសរសេរពាក្យនិយាយអំពីប្រភេទនៃ“ការធ្វើចំណាកស្រុកដោយសុវត្ថិភាព” យកមកតំរៀបជាជួរនៅលើឥដ្ឋដោយទុកចន្លោះតូចមួយរវាងក្រដាសពាក្យនីមួយៗដើម្បីអោយសិស្សអាចបោះជំហានពីលើក្រដាសពាក្យមួយទៅលើក្រដាសពាក្យមួយទៀតបានយ៉ាងងាយស្រួល ។ ពាក្យទាំងនោះគួរតែត្រូវបានផ្ដាប់ទៅនឹងឥដ្ឋ ហើយអ្នកអាចប្រើស្កុតបិទនៅផ្នែកខាងក្រោមដើម្បីជួយឱ្យក្រដាស់ពាក្យទាំងនោះជាប់នៅនឹងកន្លែង។សូមបង្កើតបន្ទាត់ស្របគ្នាមួយទៀតនៅបន្ទាប់ពីក្រដាសពាក្យទាំងនោះ រួចហើយសូមយកក្រដាសពាក្យចំនួនបួនដែលតំណាងឱ្យ “ការធ្វើចំណាកស្រុកដោយមិនមានសុវត្ថិភាព” មកតំរៀបជាជួរដោយទុកចន្លោះប្រហោងរវាពាក្យមួយទៅពាក្យមួយធំជាងមុន។ ខ្សែបន្ទាត់នេះមានន័យថាធ្វើអោយសិស្សមានការលំបាកក្នុងការឆ្លងកាត់ តាមរយៈការបោះជំហានពីពាក្យមួយទៅពាក្យមួយទៀតតាំងពីចំណុចចាប់ផ្ដើមមកម្លេះ។ ហើយត្រូវឱ្យប្រាកដថាពាក្យទាំងនេះក៏ត្រូវបានដាក់ផ្កាប់ចុះក្រោមផងដែរ។

ជំហានទី ០៣ ចែកសិស្សជាពីរក្រុម។ (ក្រុមទីមួយហៅថា “ការធ្វើចំណាកស្រុកដោយសុវត្ថិភាព” និងក្រុមទី ២ ហៅថា “ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព”) ឱ្យក្រុមនីមួយៗតម្រង់ជួរនៅពីក្រោយក្រដាសដំបូងក្នុងជួរដែលបានតំរៀប។

សកម្មភាពទី ០២គ - ល្បែងចំណាកស្រុក (បន្ត)

ជំហានទី ០៤ ពន្យល់ពីលក្ខណ្ឌ និងគោលបំណងនៃការលេងដល់ក្រុមទាំងពីរ។

- លក្ខណ្ឌ័ទី ១៖ ជើងរបស់ពួកគេអាចប៉ះតែលើក្រដាសប៉ុណ្ណោះ។ ប្រសិនបើជើងនរណាម្នាក់បានប៉ះដីនោះពួកគេត្រូវតែចាប់ផ្ដើមឡើងវិញម្ដងទៀត។

- លក្ខណ្ឌ័ទី ២៖ ក្រុមទាំងមូលត្រូវតែរួមគ្នាដោយកាន់ដៃគ្នាគ្រប់ពេលវេលាដូចជាខ្សែសង្វាក់របស់មនុស្ស។ គោលបំណង៖ ដើម្បីដើរឆ្លងទន្លេឱ្យបានលឿនតាមដែលពួកគេអាចធ្វើទៅបានតែត្រូវអនុវត្តន៍ទៅតាមលក្ខ័ណ្ឌ នៃការលេង។

ជំហានទី ០៥ ចាប់ផ្ដើមរាប់ថយក្រោយពីរ បី មកមួយ ហើយឱ្យសិស្សចាប់ផ្ដើម។ សម្គាល់៖ ក្រុមនៃ “ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព” នឹងអាចចាប់ផ្ដើមបានលឿនជាង រីឯក្រុមនៃ “ការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព” នឹងជួបឧបសគ្គច្រើន។ បញ្ឈប់ការប្រកួតភ្លាមនៅពេលដែលក្រុមទី១បានបញ្ចប់។

ជំហានទី ០៦ នាំក្រុមទាំងពីរអបអរសាទរដល់ក្រុមដែលឈ្នះគឺក្រុមនៃ “ការធ្វើចំណាកស្រុកដោយសុវត្ថិភាព” ។ ពិភាក្សាពីមូលហេតុដែល “ក្រុមគ្មានសុវត្ថិភាព” ជួបការលំបាកបែបនេះ។

សួរថា៖ “ ហេតុអ្វីបានជាក្រុមរបស់អ្នកមិនទៅដល់ទីមុនគេ ? តើមានអ្វីកើតឡើង ?”

> គំរូចំលើយ៖" ដោយសារយើងមានចន្លោះប្រហោងច្រើនពេកទើបធ្វើឱ្យពួកយើងដាច់ចេញពីជួរហើយបន្ទាប់មកយើងត្រូវចាប់ផ្ដើមឡើងវិញម្ដងហើយម្ដងទៀត។ វាស្ទើរតែធ្វើអោយពួកយើងមិនអាចទៅមុខរួច។"

ពិនិត្យមើលពាក្យនៅលើផ្លូវនីមួយៗហើយពន្យល់ពីរបៀបដែលពួកគេចូលរួមចំណែកក្នុងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ឬគ្មានសុវត្ថិភាព។

សកម្មភាពទី ០២គ

ការអំពាវនាវឱ្យធ្វើសកម្មភាព

ឱ្យសិស្សបង្កើតសេណារីយ៉ូនៃការធ្វើចំណាកស្រុកដោយប្រើវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រដូចខាងក្រោម។ សូមបញ្ចូលនូវហេតុផលថាតើហេតុអ្វីបានជាសេណារីយ៉ូនេះគឺជាឧទាហរណ៍នៃការធ្វើចំណាកស្រុកដោយសុវត្ថិភាព ឬគ្មានសុវត្ថិភាព។
សម្រាប់បញ្ហាប្រឈមបន្ថែមទៀតសូមឱ្យកុមារគិតថាប្រសិនបើពួកគេជាអ្នកដឹកនាំនៅក្នុងទីក្រុង ឬប្រទេសរបស់អ្នក។ តើពួកគេអាចធ្វើអ្វីបានខ្លះដើម្បីធ្វើឱ្យស្ថានភាពដែលគ្មានសុវត្ថិភាព ទៅជាមានសុវត្ថិភាព? តើពួកគេអាចធ្វើអ្វីបានខ្លះដើម្បីធ្វើឱ្យស្ថានភាពដែលមានសុវត្ថិភាព ទៅជាគ្មានសុវត្ថិភាព? តើអ្នកដទៃអាចនឹងមានប្រតិកម្មយ៉ាងដូចម្តេចទៅចំពោះស្ថានភាពទាំងពីរ? សុំឱ្យពួកគេពន្យល់បន្ថែមទៀតដោយប្រើវិធីសាស្ត្រដែលពួកគេបានជ្រើសរើស។

—— បង្កើតវា (សិល្បៈ)

ឱ្យសិស្សគូររូប ឬផាត់ពណ៌លើរូបភាពដែលតំណាងឱ្យការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងគ្មានសុវត្ថិភាព។ សិស្សក៏អាចធ្វើការជាមួយគ្នាដើម្បីបង្កើតផ្ទាំងរូបភាពផូស្ទ័ ឬផ្ទាំងសម្រាប់ការផ្សព្វផ្សាយ។

សម្ភារៈ ប៊ិច ខ្មៅដៃ ថ្នាំលាប ក្រដាស ក្រដាសបិទ ឬ វត្ថុផ្សេងៗដែលអាចរកបាន

—— ធ្វើសកម្មភាពអំពីវា (ការសម្តែង)

ឱ្យសិស្សធ្វើការជាក្រុមដើម្បីបង្កើតការលេង ឬការសំដែងល្ខោនដែលនិយាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងគ្មានសុវត្ថិភាព។ ពួកគេនឹងសរសេររឿងខ្លីហើយជ្រើសរើសតួអង្គចេញពីសមាជិកក្រុមនីមួយៗ ដូច្នេះគ្រប់គ្នាត្រូវបានចូលរួមទាំងអស់គ្នា។

សម្ភារៈ ប៊ិច ខ្មៅដៃ ក្រដាស និង ការស្លៀកសំលៀកបំពាក់

—— ការសរសេរវា (និក្ខេបបទ)

សិស្សនឹងធ្វើកំណត់ហេតុអំពីសេណារីយ៉ូនៃការធ្វើចំណាកស្រុកតាមរយៈការសរសេរឬការគូរ។ឱ្យពួកគេវិភាគអំពីប្រភេទនៃការធ្វើចំណាកស្រុក (ក្នុងស្រុក ក្រៅស្រុក តាមរដូវកាល និង អន្តោប្រវេសន៍) និងកំណត់ថាតើសេណារីយ៉ូរបស់ពួកគេអាចនឹងផ្លាស់ប្តូរដែរ ឬទេប្រសិនបើពួកគេជ្រើសរើសប្រភេទខុសៗគ្នានៃការធ្វើចំណាកស្រុក។ សូមឱ្យពួកគេរាប់បញ្ចូលអំពីមូលហេតុអ្វីដែលធ្វើឱ្យការធ្វើចំណាកស្រុកប្រភេទនេះមានសុវត្ថិភាព ឬគ្មានសុវត្ថិភាព។

សម្ភារៈ ប៊ិច ខ្មៅដៃ ក្រដាស

—— និយាយប្រាប់អំពីវា (តន្ត្រី)

ឱ្យសិស្សធ្វើការជាក្រុមដើម្បីបង្កើតចម្រៀងរ៉េប ឬកំណាព្យដើម្បីបង្ហាញពីអារម្មណ៍របស់ពួកគេចំពោះការធ្វើចំណាកស្រុកដោយសុវត្ថិភាពនិងគ្មានសុវត្ថិភាព។ នេះអាចជាចង្វាក់សាមញ្ញ ឬបទចម្រៀងមួយបទ ហើយសូមចែករំលែកថា "ហេតុអ្វី" បាជាពួកគេជ្រើសរើសយកប្រភេទនៃការធ្វើចំណាកស្រុកនេះដើម្បីយកមកបកស្រាយតាមរយៈតន្ត្រីរបស់ពួកគេ។

សម្ភារៈ ប៊ិច ខ្មៅដៃ ក្រដាស និង ឧបករណ៍ភ្លេង

សកម្មភាព - វគ្គទី ០៣

អំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច

សកម្មភាពទៅ ០៣ក

ភាពខុសគ្នារវាងការរក្សាការសម្ងាត់ដែលមានសុវត្ថិភាព និងមិនមានសុវត្ថិភាព

សកម្មភាព ០២ខ

ពិនិត្យមើលស្ថានភាព“ ការរក្សាការសម្ងាត់” ដែលមានសុវត្ថិភាព និងមិនមានសុវត្ថិភាពដើម្បីទទួលស្គាល់ពីសក្តានុពល និងសមត្ថភាពរបស់កុមារក្នុងការប្រាស្រ័យទាក់ទង ការគិត ការដោះស្រាយបញ្ហានិងជំនាញបំណិនជីវិត។

សម្ភារៈ

ភាពខុសគ្នារវាងសេណារីយ៉ូនៃការរក្សាការសម្ងាត់ដែលមានសុវត្ថិភាព និងការសម្ងាត់ដែលមិនមានសុវត្ថិភាព៖ ក្រដាស ឬកុំព្យូទ័រសម្រាប់បង្កើតសេណារីយ៉ូសំងាត់ថ្មីដែលមានសុវត្ថិភាពនិងមិនមានសុវត្ថិភាព។

ជំហានទី ០១ សូមអានការរក្សាការសម្ងាត់ដែលមានសុវត្ថិភាពនិងនិយាយរឿងសម្ងាត់ដែលមិនមានសុវត្ថិភាពហើយកំណត់ថាតើវាជាគឺការរក្សាការសម្ងាត់ដែលមានសុវត្ថិភាព ឬគ្មានសុវត្ថិភាព ដោយតាមរយៈការសួរសំណួរទាំងនេះ ៖

- តើអ្នកគួររក្សាការសម្ងាត់ដែរឬទេ ? ហេតុអ្វីគួររក្សា ឬហេតុអ្វីមិនគួររក្សា ?
- តើអ្នកគួរនិយាយប្រាប់នរណាម្នាក់អំពីការសម្ងាត់ដែរឬទេ ?

ជំហានទី ០២ សុំឱ្យសិស្សបង្កើតសេណារីយ៉ូអំពីការសម្ងាត់ថ្មីដែលមានសុវត្ថិភាព និងគ្មានសុវត្ថិភាពហើយឱ្យពួកគេចែករំលែកជាមួយដៃគូ ឬនៅក្នុងក្រុម។ ឱ្យពួកគេធ្វើជំហានដើម្បីឆ្លើយតបទៅនឹងសេណារីយ៉ូថ្មីម្តងទៀត។

សកម្មភាព ០៣ក - ភាពខុសគ្នារវាងការរក្សាការសម្ងាត់ដែលមានសុវត្ថិភាព និងមិនមានសុវត្ថិភាព។ (បន្ត)

សេណារីយ៉ូទី ០១

ខាយលី កំពុងតែលេងជាមួយមិត្តដ៏ល្អបំផុតរបស់នាងហើយពេលនោះនាងបានឃើញស្នាមជាំនៅលើដៃ និងជើងរបស់មិត្តនាង។មិត្តរបស់ ខាយលី បានប្រាប់នាងថាមានពេលខ្លះឪពុករបស់នាងខឹងហើយបានធ្វើឱ្យនាងឈឺចាប់។

សេណារីយ៉ូទី ០២

សមាជិកគ្រួសាររបស់ មីត ម្នាក់បានថតរូបភាពមិនសមរម្យរបស់នាង។គាត់បាននិយាយថាគាត់នឹងទិញប្រដាប់លេងឱ្យនាង ប្រសិនបើនាងមិនប្រាប់នរណាម្នាក់ឱ្យដឹងអំពីរូបថតនោះទេ។

សេណារីយ៉ូទី ០៣

ម៉ារីអូ កំពុងលេងកុំព្យូទ័រជាមួយមិត្តរបស់គាត់។ គាត់បានឃើញអ្វីមួយដែលធ្វើឱ្យគាត់មានអារម្មណ៍ថាមិនស្រួលហើយគាត់ដឹងថាឪពុកម្តាយរបស់គាត់នឹងអនុញ្ញាតឱ្យមើលវាឡើយ។

សេណារីយ៉ូទី ០៤

ពូរបស់ម៉ី បានឱ្យនាងរាំលេងនៅឯកន្លែងការងាររបស់គាត់ បន្ទាប់ម៉ីបានចេញពីរៀន។ នាងមិនទាន់គ្រប់គ្រាន់អាយុចូលក្លឹបនោះទេដូច្នេះគាត់បានប្រាប់នាងថានាងមិនអាចប្រាប់នរណាម្នាក់បានឡើយព្រោះវាគឺជាអាថ៌កំបាំងរបស់ពួកគេ។

សេណារីយ៉ូទី ០៥

យ៉ារេឌ កំពុងធ្វើបង្អែមពិសេសសម្រាប់ថ្ងៃកំណើតរបស់ឪពុកគាត់។ ម្តាយរបស់គាត់បានប្រាប់គាត់ថាកុំប្រាប់ឪពុករបស់គាត់ឱ្យដឹងអំពីបង្អែមនេះដើម្បីឱ្យគាត់មានការភ្ញាក់ផ្អើល។

សេណារីយ៉ូទី ០៦

ចៃ បានជួបជាមួយអ្នកផលិតកម្មវិធីដ៏ល្បីម្នាក់តាមរយៈក្រុមជជែកកំសាន្តលើប្រព័ន្ធអនឡាញ។ អ្នកផលិតកម្មវិធីនោះបានអញ្ជើញគាត់ឱ្យមកមើលការសម្តែងប៉ុន្តែសូមកុំប្រាប់អ្នកណាឱ្យដឹងអោយសោះ។

សេណារីយ៉ូទី ០៧

អាមីណា បានធ្វើកាតពិសេសមួយសម្រាប់ម្តាយរបស់នាងនៅឯសាលារៀនហើយនាងបានសុំឱ្យបងស្រីនាងកុំប្រាប់ម្តាយនាងអោយដឹងមុន។

សេណារីយ៉ូទី ០៨

សារ៉ា បានសម្រេចចិត្តទទួលការងារមួយបន្ទាប់នាងពីបានរៀនចប់។ នាងមិនមានកិច្ចសន្យាការងារនោះទេ។ នៅពេលដែលបើកប្រាក់ខែ ថៅកែរបស់នាងតែងតែផ្តល់ឱ្យនាងតិចជាងនូវអ្វីដែលគាត់បានសន្យាជាមួយនាង។ នាងបានមិនប្រាប់ឪពុកម្តាយរបស់នាងឱ្យដឹងទេ។

សេណារីយ៉ូទី ០៩

លី ចង់បានទូរស័ព្ទថ្មីមួយប៉ុន្តែគាត់មិនអាចមានលទ្ធភាពទិញវាដោយខ្លួនឯងបានទេ។ លី បានជួបជាមួយបុរសបរទេសចំណាស់ម្នាក់ហើយបុរសនោះបានសន្យាថាគាត់នឹងទិញឱ្យ លី ប្រសិនបើលីព្រមមកស្នាក់នៅផ្ទះជាមួយគាត់។ បើសិនជាមានអ្នកណាម្នាក់សួរ គាត់ប្រាប់លីឱ្យនិយាយថាគាត់គឺជាឪពុករបស់លី។

សេណារីយ៉ូទី ១០

ម្តាយរបស់ចយ បានសម្រេចថាពួកគេនឹងធ្វើដំណើរទៅលេងបងស្រីរបស់គាត់ (អ៊ុំស្រីរបស់ចយ) នៅក្នុងឱកាសឆ្នាំថ្មីនេះប៉ុន្តែពួកគេនឹងមិនប្រាប់ឱ្យគាត់ដឹងមុននោះទេ។ ពួកគេបានរៀបចំដំណើរកម្សាន្តនេះជាមួយបងប្អូនជីដូនមួយរបស់ ចយ ហើយបានស្នើសុំគាត់មិនឱ្យប្រាប់នរណាម្នាក់នោះទេ។

សកម្មភាពទី ០៣៦

ការស្វែងយល់អំពីការកេងប្រវ័ញ្ច

សកម្មភាព ០២៦

វគ្គនេះត្រូវបានរៀបចំឡើងដើម្បីឱ្យកុមារមានបទពិសោធន៍ ឬធ្វើជាសាក្សីអំពីការកេងប្រវ័ញ្ចនិងគំនិតនៃភាពអយុត្តិធម៌ ឬភាពមិនស្មើគ្នា។ សកម្មភាពនេះអាចធ្វើឱ្យកុមារមានអារម្មណ៍តានតឹងនៅពេលដែលការសន្យាត្រូវបានបំភ្លេច ហើយផ្តល់ឱកាសសម្រាប់ការសន្ទនាដោយបើកចំហនិងដោយស្មោះត្រង់អំពីការកេងប្រវ័ញ្ច។

សម្ភារ

រង្វាន់តូចៗប្រហែល ៥-១០ (ឧទាហរណ៍ដូចជា៖ ស្ទីគ័រ ឬស្ករគ្រាប់)។

ជំហានទី ០១ ពិភាក្សាអំពីថាតើសកម្មភាពនេះនឹងជួយយើងឱ្យយល់ពីគំនិតនៃភាពអយុត្តិធម៌ដោយរបៀបណា។

សួរថា៖ "តើអ្នកណាអាច អាវ៉ង់ដីបាន?"
*ជ្រើសរើសអ្នកស្ម័គ្រចិត្តពីរនាក់ពីក្នុងចំណោមអ្នកចូលរួមដែលបានឆ្លើយថាពួកគេអាច អាវ៉ង់បាន ហើយសន្យាជាមួយអ្នកស្ម័គ្រចិត្តទាំងពីរនេះថា ពួកគេនឹងទទួលបានរង្វាន់ (ឧទាហរណ៍៖ ស្ទីគ័របិត ឬស្ករគ្រាប់) នៅពេលពួកគេបានបំពេញការងារជាក់លាក់។

ជំហានទី ០២ ឱ្យអ្នកស្ម័គ្រចិត្តទាំងពីរ អាវ៉ង់ដីចំនួន ៣ ដង (ឬកិច្ចការផ្សេងទៀត)។ នៅពេលដែលពួកគេបានបញ្ចប់ការអាវ៉ង់ចំនួន០៣ដង គឺមានតែអ្នកស្ម័គ្រចិត្តម្នាក់ប៉ុណ្ណោះដែលទទួលបានស្ទីគ័របិត។ សុំឱ្យពួកគេធ្វើការ ការអាវ៉ង់ដីចំនួនបីដងបន្ថែមទៀត។ នៅពេលពួកគេបានបញ្ចប់ ផ្តល់រង្វាន់ឱ្យតែអ្នកស្ម័គ្រចិត្តដូចគ្នាដោយមិនអើពើនឹងអ្នកផ្សេងទៀតឡើយ។

សួរថា៖ "តើអ្នកគិតថាវាយុត្តិធម៌ដែរឬទេ? ហេតុអ្វីយុត្តិធម៌ ឬហេតុអ្វីមិនយុត្តិធម៌?"

> គំរូចម្លើយ៖ ទេ! វាហាក់ដូចជាមិនយុត្តិធម៌ទាល់តែសោះ។ ទោះបីជាពួកគេទាំងពីរបានធ្វើការអាវ៉ង់ដីចំនួន៣ដងក៏ដោយក៏មានមនុស្សតែម្នាក់ប៉ុណ្ណោះដែលត្រូវបានទទួលនូវស្ទីគ័របិទ។

ជំហានទី ០៣ ធ្វើជំហានទី០២ ម្តងទៀត ដោយផ្តល់រង្វាន់ដល់អ្នកស្ម័គ្រចិត្តដូចគ្នា និងមិនអើពើពីអ្នកផ្សេងឡើយ។

ជំហានទី ០៤ ពន្យល់ពីសកម្មភាពដែលជាឧទាហរណ៍នៃការកេងប្រវ័ញ្ចនិងពីរបៀបដែលវាអាចជាទម្រង់នៃការស្នើសុំឱ្យនរណាម្នាក់បំពេញភារកិច្ច (ឧទាហរណ៍៖ ការងារ) ដោយសន្យាថានឹងផ្តល់រង្វាន់ដល់ពួកគេ (ឧទាហរណ៍៖ប្រាក់ឈ្នួល) ហើយបន្ទាប់មកមិនឱ្យតាមការសន្យារបស់ពួកគេនោះទេ។នៅក្នុងសកម្មភាពនេះ កិច្ចការដែលត្រូវធ្វើគឺត្រូវជំរុញដើម្បីឱ្យទទួលបានរង្វាន់។ ខណៈពេលដែលអ្នកស្ម័គ្រចិត្តទាំងពីរត្រូវបានសន្យាថានឹងទទួលរង្វាន់អោយដូចគ្នាមានតែមនុស្សម្នាក់ប៉ុណ្ណោះដែលទទួលបានរង្វាន់។

ជំហានទី ០៥ ផ្តល់រង្វាន់ពីរដល់អ្នកស្ម័គ្រចិត្តដែលមិនបានទទួល ហើយអរគុណដល់អ្នកស្ម័គ្រចិត្តទាំងពីរដែលបានចូលរួម។នៅពេលពួកគេកំពុងវិលត្រឡប់ទៅរកកន្លែងអង្គុយរបស់ពួកគេវិញសូមនិយាយដូចតទៅ៖ "ពេលខ្លះមនុស្សយើងត្រូវបានគេសន្យាផ្តល់ឱកាសការងារ កន្លែងធ្វើការងារ និងប្រាក់ខែដែលមិនពិត ពោលគឺត្រូវបានគេកុហក់ និងបោកប្រាស់។ដូច្នេះពួកគេធ្វើការដោយមិនបានទទួលប្រាក់ខែសោះ។ក្នុងស្ថានភាពជាច្រើនដែលពួកគេមិនអាចចាកចេញបានទេ ។ មនុស្សគ្រប់គ្នាសមនឹងទទួលបាននូវប្រាក់ឈ្នួលសម្រាប់ការខិតខំបំពេញការងារ របស់ពួកគេ ហើយពួកគេសមនឹងទទួលបាននូវលក្ខខណ្ឌការងារដែលល្អ។នៅពេលដែលមនុស្សណាម្នាក់ត្រូវបានគេបង្ខំឱ្យធ្វើការដោយគ្មានប្រាក់ឈ្នួលហើយមិនមានសេរីភាពក្នុងការចាកចេញ នោះយើងអោយឈ្មោះថាជាពលកម្មដោយបង្ខំ ដែលជាទម្រង់មួយនៃការជួញដូរមនុស្ស ។ នៅពេលដែលរឿងនេះកើតឡើង ហើយជាប់ពាក់ព័ន្ធទៅនឹងកុមារនោះយើងហៅថាគឺជាការជួញដូរកុមារ"។

ផ្នែក ០៣

សកម្មភាព ០៣គ

តើអ្នកនឹងធ្វើអ្វី ?

សកម្មភាព ០២ខ

ដើម្បីណែនាំពីទម្រង់មូលដ្ឋាននៃការកេងប្រវ័ញ្ច និងការជួញដូរមនុស្សដែលជាបទឧក្រិដ្ឋនិងការរំលោភលើសិទ្ធិមនុស្ស។

សម្ភារៈ

រូបតំណាងនៃការជួញដូរមនុស្ស ជាជំរើស៖ ក្រដាស ក្រដាសក្រាយ៉ុង ខ្មៅដៃ។

ជំហានទី ០១ ពិភាក្សាអំពីនិយមន័យនៃអំពើជួញដូរមនុស្ស។ ទម្រង់នៃការកេងប្រវ័ញ្ចគឺជាបទឧក្រិដ្ឋនៃការធ្វើពាណិជ្ជកម្មខុសច្បាប់លើមនុស្សជាពិសេសក្នុងគោលបំណងដើម្បីកេងប្រវ័ញ្ចលើកម្លាំងពលដោយបង្ខំ និងការជួញដូរផ្លូវភេទ។ ការជួញដូរកុមារគឺជាការជួញដូរមនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំ ។

សួរថា៖“ តើប្រភេទនៃការជួញដូរមនុស្សមានអ្វីខ្លះ ?”
កត់ត្រាការឆ្លើយតប និងណែនាំអំពីប្រភេទនៃការជួញដូរនីមួយៗដោយប្រើរូបតំណាង និងនិយមន័យដែលបានផ្តល់ឱ្យ។ ប្រៀបធៀបចំនុចដូចនិងចំនុចខុសគ្នារវាងប្រភេទនៃការជួញដូរនីមួយៗ ហើយពន្យល់ពីរបៀបដែលអំពើជួញដូរមនុស្សគឺជាទាសភាពសម័យទំនើប។

ជំហានទី ០២ ឱ្យសិស្សជ្រើសរើសប្រភេទនៃការជួញដូរមនុស្សមួយប្រភេទដើម្បីយកមកបង្ហាញ។ នៅក្នុងក្រុម សូមឱ្យពួកគេពិភាក្សាពីរបៀបនិងហេតុអ្វីបានជាការជួញដូរប្រភេទនេះត្រូវបានគេចាត់ទុកថាជាបទឧក្រិដ្ឋ។

ប្រភេទនៃការជួញដូរមនុស្ស

- **ការងារដោះបំណុល៖** គឺជាការបង្ខំឱ្យមនុស្សម្នាក់ធ្វើការដើម្បីទទួលបានប្រាក់ឈ្នួលទាបដើម្បីសងបំណុល។
- **ទាហានកុមារ៖** គឺជាការបង្ខំកុមារឱ្យចូលរួមក្នុងកងកម្លាំងប្រដាប់អាវុធ ។
- **ការជួញដូរកុមារ៖** គឺជាប្រភេទនៃការជួញដូរមនុស្សដែលពាក់ព័ន្ធទៅនឹងនរណាម្នាក់ដែលមានអាយុក្រោម ១៨ ឆ្នាំ។
- **ពលកម្មដោយបង្ខំ៖** គឺជាការបង្ខំឱ្យនរណាម្នាក់ធ្វើការដោយស្ថិននៅក្នុងការឃុំឃាំងដោយទទួលបានប្រាក់ខែតិចតួច ឬគ្មានប្រាក់ខែ។
- **ការងារបម្រើតាមផ្ទះដោយមិនស្ម័គ្រចិត្ត៖** គឺជាការបង្ខំនរណាម្នាក់ឱ្យធ្វើការនិងរស់នៅកន្លែងតែមួយដោយទទួលបានប្រាក់ខែតិចតួច ឬ គ្មានប្រាក់ខែ។

<u>កំណត់សំគាល់សម្រាប់អ្នកសម្របសម្រួល៖</u> វាអាស្រ័យលើអាយុនៃសិស្សរបស់អ្នក ព្រោះនិយមន័យនេះប្រហែលជាមិនសមរម្យក្នុងការចែករំលែកនោះទេ។

- **ការជួញដូរផ្លូវភេទ៖** គឺការបង្ខំ ឬការបោកបញ្ឆោត ឬបង្ខិតបង្ខំមនុស្សឲ្យនរណាម្នាក់ប្រកបអាជីវកម្មផ្លូវភេទដោយបង្ខំ។ ការជំរុញនរណាម្នាក់ដែលមានអាយុក្រោម ១៨ ឆ្នាំធ្វើសកម្មភាពបែបនេះ។

ជំហានទី ០៣ ពន្យល់ថាការជួញដូរមនុស្សគឺជាបទឧក្រិដ្ឋមួយដែលអាចកើតឡើងចំពោះមនុស្សគ្រប់គ្នា ដូច្នេះហើយវាគឺជាការសំខាន់ណាស់ដែល អ្នកត្រូវដឹងថា តើអ្នកត្រូវធ្វើយ៉ាងម៉េចប្រសិនបើអ្នកមានអារម្មណ៍ថាមិនមានសុវត្ថិភាព ឬមិនស្រួល ។ ពិភាក្សាពីភាពខុសគ្នារវាងមនុស្សដែលមាន "កលល្បិច" និងមនុស្សដែលអាចជឿទុកចិត្តបាន ហើយសិស្សគួរតែប្រាប់នរណាម្នាក់ដែលពួកគេជឿទុកចិត្តប្រសិនបើពួកគេអារម្មណ៍ថាមិនមានសុវត្ថិភាព។

សកម្មភាពទី ០៣គ - តើអ្នកនឹងត្រូវធ្វើដូចម្ដេច? (បន្ត)

ជំហានទី ០៤ សូមអានសេណារីយ៉ូខាងក្រោមហើយប្រាប់សិស្សឱ្យចែកចាយនូវអ្វីដែលពួកគេនឹងធ្វើប្រសិនបើពួកគេស្ថិតក្នុងស្ថានភាពណាមួយ។ ពិភាក្សាជាក្រុមដើម្បីឆ្លើយតបប្រកបដោយសុវត្ថិភាព។ បន្ទាប់មកកំណត់អត្តថាតើការជួញដូរមនុស្សប្រភេទណាដែលងាយនឹងកើតឡើងដោយផ្អែកទៅលើសេណារីយ៉ូដែលបានបង្ហាញ។

សេណារីយ៉ូទី ០១

អ្នកកំពុងលេងនៅលើផ្លូវខាងមុខផ្ទះរបស់អ្នកជាមួយមិត្តភក្ដិរបស់អ្នក។ ពេលនោះមានគូស្នេហ៍មួយដែលមានភាពរួសរាយរាក់ទាក់ បានបើកឡានចេញខាងមុខផ្ទះរបស់អ្នក ហើយអើតតាមកញ្ចក់ឡានដោយនិយាយប្រាប់អ្នកទាំងសោកសៅថាពួកគេបានបាត់ឆ្កែ។អ្នកមិនដែលស្គាល់ ឬឃើញមុខអ្នកជិតខាងរបស់ពួកគេនោះទេ ហើយពួកគេបានសុំអោយអ្នកឡើងជិះឡានដើម្បីជួយដើររកឆ្កែនៅជុំវិញនោះ។ ពួកគេនឹងឱ្យអ្នក១០ដុល្លារប្រសិនបើអ្នកយល់ព្រមទៅជាមួយពួកគេដើម្បីជួយស្វែងរកកូនឆ្កែរបស់ពួកគេ។ តើអ្នកនឹងធ្វើអ្វី?

សេណារីយ៉ូទី ០២

មិត្តរបស់អ្នកម្នាក់ឈ្មោះអ៊ីសាបេឡា បានជជែកជាមួយមិត្តភក្ដិថ្មីៗរបស់គាត់ តាមរយៈហ្វេសប៊ុក។ ពេលនោះនាងបាននិយាយជាមួយមិត្តម្នាក់ តាមរយៈការលេងហ្វេសប៊ុកដែលនាមិនដែលស្គាល់គេពីមុនសោះ តែគេមើលទៅដូចជាបុរសវ័យក្មេងនិងសង្ហារម្នាក់ ។ ឈ្មោះរបស់ គាត់គឺជេក។ក្រោយមកតាមរយៈការសន្ទនារគ្នាចុះឡើង ជេកក៏បានសុំណាត់ អ៊ីសាបេឡាឱ្យទៅជួបនៅឯផ្សារតូចមួយនៅក្នុងភូមិ ។គាត់ថែមទាំងបានប្រាប់ឱ្យឲ្យអ៊ីសាបេឡានាំមិត្តរបស់នាងម្នាក់ទៀតមកជាមួយផង ។ អ៊ីសាបេឡា ដឹងថាឪពុកម្ដាយរបស់នាងនឹងមិនយល់ព្រមចំពោះការណាត់ជួបនេះទេ ។ តើអ្នកនឹងធ្វើអ្វី?

សេណារីយ៉ូទី ០៣

មិត្តរបស់អ្នកម្នាក់ឈ្មោះ ចៃ បានអញ្ជើញអ្នកទៅចូលរួមពិធីជប់លៀងនៅផ្ទះរបស់គាត់បន្ទាប់ពីចេញពីសាលារៀន ។ មានមិត្តភក្ដិរបស់អ្នកជាច្រើន មានគម្រោងចង់ទៅចូលរួមដែរ ។ ម្ដាយរបស់អ្នកកំពុងជាប់រវល់ធ្វើការ ដូច្នេះ ចៃ បានអញ្ជើញអ្នកឱ្យទៅជិះទៅផ្ទះជាមួយគាត់ និងម្ដាយរបស់គាត់ បន្ទាប់ពីចេញពីសាលារៀន ។ ម្ដាយរបស់អ្នកក៏បានយល់ព្រម។ ពេលចេញពីរៀន មានបុរសម្នាក់បាននិយាយថាគាត់ជាពូរបស់ ចៃ ដែលទើបតែមកពីខាងក្រៅទីក្រុងមកទទួល ចៃ និងអ្នកទៅផ្ទះជំនួសម្ដាយរបស់ចៃ។ ចៃ ហាក់ដូចជាមិនសប្បាយចិត្តទេនៅពេលដែលបានឃើញពូរបស់គាត់។ តើអ្នកនឹងធ្វើអ្វី?

សេណារីយ៉ូទី ០៤

អ្នកសំរេចចិត្តជិះកង់ដើរលេងជាមួយនឹងមិត្តរបស់អ្នកនៅផ្ទះអ្នកជិតខាង។ នៅពេលអ្នកកំពុងជិះកង់របស់អ្នកស្រាប់តែមានឡានមួយបើកយឺតៗតាមពីក្រោយអ្នក។អ្នកកំពុងតែស្ថិតនៅទីកន្លែងមួយដែលអ្នកមិនធ្លាប់ស្គាល់ ហើយផ្ទះរបស់អ្នកទាំងពីរនៅឆ្ងាយទៀត។ តើអ្នកនឹងធ្វើអ្វី?

សេណារីយ៉ូទី ០៥

ខ្សែភាពយន្តបានចប់តែអ្នកនិងមិត្តរបស់អ្នកកំពុងស្ថិតនៅរោងកុនដើម្បីរង់ចាំឪពុកម្ដាយរបស់អ្នកមកទទួលយកទៅផ្ទះ។ ពេលនោះមានសុភាពបុរសម្នាក់បានដើរមករកអ្នក ហើយនិយាយថាគេចង់ជូនអ្នកទៅផ្ទះ។ អ្នកបានប្រាប់គាត់ថាទេ ពីព្រោះឪពុកម្ដាយរបស់អ្នកនឹងមកដល់ទីនោះឆាប់ៗ។ គាត់នៅតែទទូចចង់ជូនអ្នកទៅផ្ទះដោយចាប់ទាញកែងដៃអ្នក ហើយជំរុញឱ្យអ្នកដើរឆ្ពោះទៅរកឡានរបស់គាត់។ តើអ្នកនឹងធ្វើអ្វី ?

សេណារីយ៉ូទី ០៦

ម្ដាយរបស់អ្នកបានទៅផ្សារដើម្បីទិញគ្រឿងទេសមួយចំនួនសម្រាប់រៀបចំអាហារពិសេសដែលគាត់នឹងត្រូវចំអិននៅពេលល្ងាចនេះ។គាត់នឹងទៅផ្សារដែលនៅជិតផ្ទះរបស់អ្នក ហើយគាត់ត្រូវចំណាយពេលតែពីរ ឬបីនាទីប៉ុណ្ណោះ។ នៅពេលនោះ អ្នកបានលឺនរណាម្នាក់កំពុងតែគោះទ្វារ។ អ្នកបានឃើញមនុស្សដែលអ្នកមិនបានអញ្ជើញឈរនៅមាត់ទ្វាររបស់អ្នក។ តើអ្នកនឹងធ្វើអ្វី ?

សេណារីយ៉ូទី ០៧

អ្នកកំពុងលេងអ៊ីនធឺណេិត ហើយពេលនោះស្រាប់តែមានមនុស្សចម្លែកម្នាក់បានអែតមកសុំធ្វើជាមិត្តរបស់អ្នកហើយអ្នកក៏បានយល់ព្រម។ ពីរបីថ្ងៃក្រោយមកពួកគេចាប់ផ្ដើមជជែកជាមួយអ្នកហើយមើលទៅពួកគេដូចជារួសរាយរាក់ទាក់ណាស់។ ពួកគេសួរថាតើអ្នកចង់ប្រើវេបខេមដែរឬទេ ដើម្បីឱ្យអ្នកនឹងពួកគេអាចមើលឃើញគ្នាបាន។ តើអ្នកនឹងធ្វើអ្វី ?

សេណារីយ៉ូទី ០៨

ឪពុកម្ដាយរបស់អ្នកបានប្រាប់អ្នកឱ្យលក់កន្ត្រកផ្កាឲ្យអស់នៅត្រឹមពេលល្ងាច បើមិនដូច្នោះទេអ្នកមិនអាចត្រលប់មកផ្ទះបានទេ។ តើអ្នកនឹងធ្វើអ្វី ?

សេណារីយ៉ូទី ០៩

មានមនុស្សចម្លែកម្នាក់មករកអ្នក ហើយបាននិយាយថាគេនឹងទិញកុំព្យូទ័រយួរដៃឱ្យអ្នកមួយគ្រឿង (ទូរស័ព្ទចល័ត ឬឡានជ័រ) ព្រមទាំងឱ្យលុយចាយខ្លះទៀតផង ប៉ុន្តែអ្នកត្រូវតែមកធ្វើការឱ្យគេ។ តើអ្នកនឹងធ្វើអ្វី ?

សេណារីយ៉ូទី ១០

អ្នកកំពុងតែញ៉ាំអាហារពេលល្ងាចជាមួយឪពុកម្ដាយរបស់អ្នកពេលនោះក៏ឃើញក្មេងស្រីតូចម្នាក់កំពុងលក់ផ្កាឱ្យទៅបុរសម្នាក់។ បុរសនោះបានឱ្យលុយទៅនាងដើម្បីទិញយកផ្កានោះទាំងអស់ បន្ទាប់មកគាត់ក៏ចាប់ផ្ដើមប៉ះពាល់រាងកាយនាង។ តើអ្នកនឹងធ្វើអ្វី ?

សេណារីយ៉ូទី ១១

អ្នកកំពុងនៅឯសាលារៀនជាមួយមិត្តរបស់អ្នក នៅពេលនោះពួកគេបាននិយាយប្រាប់អ្នកពីនរណាម្នាក់នៅក្នុងគ្រួសាររបស់ពួកគេបានប៉ះពាល់បែបមិនសមរម្យមកលើរាងកាយរបស់ពួកគេខណៈពេលដែលគ្មាននរណាម្នាក់នៅជិតអ្នកឡើយ (ពួកគេជាមនុស្សគួរអោយស្អប់ / មានល្បិចកល) ។ តើអ្នកនឹងធ្វើអ្វី ?

សកម្មភាពទី ០៣គ

ការអំពាវនាវឱ្យធ្វើសកម្មភាព

សូមអានសេណារីយ៉ូនៃអំពើជួញដូរមនុស្សខាងក្រោម (ឬមើលវីដេអូ តើអ្នកអាចមើលខ្ញុំដែរឬទេ? នឹងដំណរភ្ជាប់ទៅកាន់ជនជានឯកសារនៅក្នុងវគ្គទី០៣) ។អញ្ជើញសិស្សឱ្យឆ្លើយតបនិងជ្រើសរើសវិធីសាស្ត្រមួយក្នុងចំណោមវិធីខាងក្រោមដើម្បីឆ្លើយតបនឹងទស្សនៈនៃអំពើជួញដូរមនុស្ស។ ចំពោះបញ្ហាប្រឈមបន្ថែមទៀត សូមឱ្យកុមារគិតអំពីសេណារីយ៉ូដែលពួកគេបានសរសេរនិងបង្ហាញពីកត្តាជំរុញចំនួនពីរនិងកត្តាអូសទាញចំនួនពីរ។ នៅពេលដែលពួកគេបានកំណត់កត្តាទាំងនេះហើយ សូមសួរពួកគេថាតើពួកគេអាចធ្វើអ្វីបានដើម្បីការពារប្រជាជនឱ្យបានល្អប្រសើរជាងនេះ? អញ្ជើញពួកគេឱ្យពន្យល់បន្ថែមទៀតដោយប្រើវិធីសាស្ត្រដែលពួកគេបានជ្រើសរើស។

សេណារីយ៉ូ អំពីការជួញដូរកម្លាំងពលកម្ម

ខណៈពេលដែលគេបានធ្វើដំណើរឆ្លងកាត់ទូទាំងប្រទេសរបស់គាត់ លោក អានតុន ត្រូវបានគេផ្តល់ឱកាសឱ្យទៅធ្វើការនៅក្រៅប្រទេស ។ គាត់មានក្តីរំភើបរីករាយនិងបានទទួលយកឱកាសនេះ។ ប៉ុន្តែលោកអានតុន ត្រូវបានគេកុហកបោកប្រាស់ទេ។ នៅពេលគាត់ទៅដល់ អ្វីៗទាំងអស់គឺខុសពីការដែលគេបានសន្យាជាមួយគាត់។ឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ត្រូវបានគេដុតចោលហើយគាត់ត្រូវបានអ្នកជួញដូរវាយដំ។ ពួកគេបានបង្ខំឲ្យគាត់ធ្វើការនៅក្នុងរោងចក្រ នៅឯកសិដ្ឋាន និងធ្វើការងារតាមផ្ទះដោយទទួលបានប្រាក់ខែតិចតួច ឬគ្មានប្រាក់ខែទាល់តែសោះ។ គាត់ត្រូវបានគេធ្វើឱ្យក្លាយទៅជាទាសករ និងត្រូវបានគេរំលោភបំពានអស់រយៈពេល០៣ឆ្នាំ។ បន្ទាប់ពីការប៉ុនប៉ងលួចរត់ជាច្រើនដង នៅទីបំផុត លោកអានតុន ក៏អាចរត់គេចខ្លួនបាន។ ចាប់ពីពេលនេះតទៅគាត់លែងរស់នៅក្នុងភាពជាទាសករទៀតហើយ។

បង្កើតវា (សិល្បៈ)

ឱ្យសិស្សគូររូប ឬផាត់ពណ៌រូបភាពដែលមើលទៅតំណាងឱ្យការជួញដូរ និងការកេងប្រវ័ញ្ចដូចជា (ឧទាហរណ៍៖ ទម្រង់មួយក្នុងចំណោមទម្រង់សំខាន់ៗនៃអំពើជួញដូរមនុស្ស) ឬអំពីអត្ថន័យរបស់វា។ សិស្សក៏អាចធ្វើការជាមួយគ្នាដើម្បីបង្កើតផ្ទាំងរូបភាព ផូស្ទឺ ឬផ្ទាំង ផ្សព្វផ្សាយពានិជ្ជកម្ម។

សម្ភារៈ ប៊ិច ខ្មៅដៃ ថ្នាំលាប ក្រដាស ស្ទីគ័រ ពណ៌ ឬ វត្ថុផ្សេងៗដែលអាចរកបាន

ធ្វើសកម្មភាពអំពីវា (ការសម្តែង)

ឱ្យសិស្សធ្វើការជាក្រុមដើម្បីបង្កើតការសម្តែងល្ខោន ឬរឿងនិទានមួយដោយផ្អែកលើការសម្ភាត់ជុំវិញការជួញដូរនិងកេងប្រវ័ញ្ចមនុស្ស។ ពួកគេត្រូវបានគេរំពឹងថានឹងសរសេររឿងសង្ខេបខ្លីមួយដែលបង្ហាញពីអ្វីដែលពួកគេចង់ធ្វើហើយបន្ទាប់មកជ្រើសរើសតួអង្គដោយបានត្រឹមត្រូវក្នុងចំណោមសមាជិកម្នាក់ៗនៃក្រុមរបស់ពួកគេ ដូច្នេះសិស្សទាំងអស់ត្រូវបានចូលរួមទាំងអស់គ្នា ។

សម្ភារៈ ប៊ិច ខ្មៅដៃ ក្រដាស កាស្លៀកពាក់សំលៀកបំពាក់ ។ល។

សកម្មភាពទី ០៣គ - ការអំពាវនាវឱ្យធ្វើសកម្មភាព (បន្ត)

ការសរសេរវា (និក្ខេបបទ)

ឱ្យសិស្សធ្វើការជាក្រុមដើម្បីបង្កើតការសម្តែងល្ខោន ឬរឿងនិទានមួយដោយផ្អែកលើការសម្ភាត់ជុំវិញការជួញដូរនិងកេងប្រវ័ញ្ចមនុស្ស។ ពួកគេត្រូវបានគេរំពឹងថានឹងសរសេររឿងសង្ខេបខ្លីមួយដែលបង្ហាញពីអ្វីដែលពួកគេចង់ធ្វើហើយបន្ទាប់មក ជ្រើសរើសតួអង្គដោយបានត្រឹមត្រូវក្នុងចំណោមសមាជិកម្នាក់ៗនៃក្រុមរបស់ពួកគេ ដូច្នេះសិស្សទាំងអស់ត្រូវបានចូលរួមទាំងអស់គ្នា ។

សម្ភារ: ប៊ិច ខ្មៅដៃ ក្រដាស កាស្លៀកពាក់សំលៀកបំពាក់ -ល។

ប្រាប់អំពីវា (តន្ត្រី)

ឱ្យសិស្សទាំងអស់ធ្វើកំណត់ហេតុអំពីសេណារីយ៉ូនៃការជួញដូរមនុស្ស និងពីរបៀបដែលពួកគេនឹងត្រូវឆ្លើយតបចំពោះសេណារីយ៉ូនេះ។ សកម្មភាពនេះអាចធ្វើតាមរយៈការសរសេរឬគូរគំនូរ ដែលចេញពីគំនិត និងការច្នៃប្រឌិតផ្ទាល់ខ្លួនរបស់ពួកគេ។

សម្ភារ: ប៊ិច ខ្មៅដៃ ក្រដាស

ធនធាននិងឯកសារយោង



ឯកសារយោង

- អង្គការពលកម្មអន្តរជាតិ (ឆ្នាំ ២០១២) ។ ការប៉ាន់ប្រមាណថ្មីរបស់ អាយ អិល អូ .ពលកម្មដោយបង្ខំ៖ ២០.៩ លាននាក់ជនរងគ្រោះ។ ទាញយកពី http://www.ilo.org/global/topics/forced-labour/news/WCMS_182109/lang--en/index.html
- អង្គការពលកម្មអន្តរជាតិនិងមូលនិធិដើម្បីសេរីភាព។ (ឆ្នាំ ២០១៧) ។ ការប៉ាន់ស្មានជាសកលនៃទាសភាពសម័យទំនើប: ការងារដោយបង្ខំ និងអាពាហ៍ពិពាហ៍ដោយបង្ខំ។ ទាញយកពី http://www.ilo.org/wcmsp5/groups/public/@dgreports/@dcomm/documents/publication/wcms_575479.pdf
- អង្គការទេសន្តរប្រវេសន៍អន្តរជាតិ ។ (២០១៩) Retrieved from https://migrationdataportal.org/?i=stock_abs_&t=2019
- Rogowski, R. (2013). ។ ទាសភាព: គំរូដែលមានលំនឹងពីរជាមួយឧទាហរណ៍ប្រវត្តិសាស្ត្រមួយចំនួន។ ជម្រើសសាធារណៈ:។ V. ១៥៥, ៣-៤, (ទំព័រ ១៨៩-២០៩) DOI ១០.១០០៧ / s១១១២៧-០១១-៩៨៧០-៣
- Schottenhammer, A. (2003) ទាសភាព និងទម្រង់នៃទាសភាពនៅចុងអធិរាជចិន (សតវត្សទី ១៧ដល់ដើមសតវត្សរ៍ទី ២០) ទាសភាពនិងការលុបបំបាត់ចោល៖ ទិនានុប្បវត្តិនៃការសិក្សាទាសភាពនិងក្រោយទាសករ 24: 2, 143-154, DOI: 10.1080 / ០១៤៤០៣៩០៣០៨៥៥៩១៦១
- ធនាគារពិភពលោក (ឆ្នាំ ២០១៩) ។ ភាពក្រីក្រ http://www.worldbank.org/en/topic/poverty/overview
- គោលដៅរបស់អង្គការសហប្រជាជាតិ (ឆ្នាំ ២០១៧) គោលដៅទី ១៖ បញ្ចប់ភាពក្រីក្រនៅគ្រប់ទម្រង់ទាំងអស់នៅគ្រប់ទីកន្លែង http://www.un.org/sustainabledevelopment/poverty/
- អង្គការសហប្រជាជាតិនាយកដ្ឋានកិច្ចការសេដ្ឋកិច្ចនិងសង្គម។ (ឆ្នាំ ២០១៧) ។ របាយការណ៍អន្តោប្រវេសន៍អន្តរជាតិឆ្នាំ ២០១៧ ។ pdf " http://www.un.org/en/development/desa/population/migration/publications/migrationreport/docs/MigrationReport2017_Highlights.pdf
- កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។ (ឆ្នាំ ២០១៧) ។ គោលដៅទី ៤ គោលដៅ។ ទាញយកពី http://www.undp.org/content/undp/en/home/sustainable-development-goals/goal-4-quality-education/targets/
- អង្គការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ (យូណេស្កូ) ឆ្នាំ ២០១៧ ។ កាត់បន្ថយភាពក្រីក្រជាសកលតាមរយៈការអប់រំបឋមសិក្សានិងមធ្យមសិក្សាសកល។ ទាញយកពី http://uis.unesco.org/sites/default/files/documents/reducing-global-poverty-through-universal-primary-secondary-education.pdf
- យូណេស្កូ។ (ឆ្នាំ ២០១៧) ។ អំពើហិង្សានិងការសម្លុតនៅតាមសាលារៀន៖ របាយការណ៍ស្ថានភាពសកលឆ្នាំ២០១៧។ http://unesdoc.unesco.org/images/0024/002469/246970e.pdf
- កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអិនឌីភី) (២០១៨) គោលដៅទី ៤៖ ការអប់រំប្រកបដោយគុណភាព។ ដកស្រង់ចេញពី http://www.undp.org/content/undp/en/home/sustainable-development-goals/goal-4-quality-education.html
- យូអិនឌីភី។ (២០១៧) ។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព http://www.undp.org/content/undp/en/home/sustainable-development-goals.html

ឯកសារយោង បន្ត

- **អង្គការសុខភាពពិភពលោក។ (២០១៩) ។ សុខភាពផ្លូវចិត្ត៖ ទិន្នន័យធ្វើអត្តឃាត**
  https://www.who.int/mental_health/prevention/suicide/estimates/en/
- **អង្គការសុខភាពពិភពលោក (ឆ្នាំ ២០១៤) ។ ការការពារពីការធ្វើអត្តឃាត៖ ជាកិច្ចការចាំបាច់ជាសកល។** ដកស្រង់ចេញពី
  https://www.who.int/mental_health/suicide-prevention/world_report_2014/en/
- Zelnick-Abramovitz, R. (ឆ្នាំ ២០០៩) ទាសករដែលត្រូវបានដោះលែងនិងស្ថានភាពរបស់ពួកគេ និងការគ្រប់គ្រងរដ្ឋរបស់ពួកគេនៅប្រទេសក្រិកសម័យ បុរាណ ការពិនិត្យប្រវត្តិសាស្ត្រអឺរ៉ុប: ការពិនិត្យឡើងវិញនូវប្រវត្តិសាស្ត្រអឺរ៉ុប៖ ១៦, ៣, ៣០៣- ៣១៨. , doi: 10.1080 / 13507480902916779

ធនធាននានា

វគ្គទី ០១

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UNUDHR)៖ https://www.un.org/en/udhrbook/pdf/udhr_booklet_en_web.pdf
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC)៖ https://www.ohchr.org/en/professionalinterest/pages/crc.aspx
- សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ៖ https://www.un.org/en/sections/issues-depth/human-rights/
- ការការពារកុមាររបស់យូនីសេហ្វ អ៊ីអេភីអរអូ ទីក្រុងបាងកកក្នុងយុគសម័យឌីជីថល៖ https://www.unicef.org/csr/files/Child_Protection_in_the_Digital_Age.pdf
- អត្ថបទស្តីអំពីការកេងប្រវ័ញ្ច៖ https://plato.stanford.edu/archives/sum2017/entries/exploitation/
- វីដេអូយូធូបរបស់អង្គការយូនីសេហ្វដែលមានចំណងជើង សួស្តីកុមារ - ស្វែងយល់អំពីសិទ្ធិរបស់កុមារ៖ https://www.youtube.com/watch?v=dGzbmf8NEto

វគ្គទី ០២

- អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) https://www.iom.int
- អង្គការពលកម្មអន្តរជាតិ (ILO) http://www.ilo.org/global/lang--en/index.htm
- ទិន្នន័យអំពីការធ្វើចំណាកស្រុក៖ https://migrationdataportal.org/?t=2019&i=stock_abs_
- អត្ថបទស្តីអំពីការរើសអើង៖ https://plato.stanford.edu/archives/win2016/entries/discrimination/

វគ្គទី ០៣

- ការសម្ងាត់ល្អ និង មិនល្អ - វីដេអូក្មេងប្រុស១៖ https://www.youtube.com/watch?v=hYlUT5CBXCo
- **Yell & Tell - by Createfuturegood:** https://www.youtube.com/watch?v=oTS6C6yafMM
- វីដេអូស្តីអំពីប្រវត្តិនៃទាសភាព៖ https://www.youtube.com/watch?v=ra6Bs_VpsBw
- **NetSmartz Kids:** http://www.netsmartzkids.org
- **Wolak J, Finkelhor D, Mitchell K, Ybarra M.** អ្នកព្យាបាល "លើអ៊ីនធឺណែតនិងជនរងគ្រោះ៖ ទេវកថា, តថភាព និងផលប៉ះពាល់សម្រាប់ការការពារនិងការព្យាបាល។ ចិត្តវិទ្យាអាមេរិចឆ្នាំ ២០០៨; ៦៣, ១១១-១២៨៖ https://www.apa.org/pubs/journals/releases/amp-632111.pdf
- វីដេអូដែលមានចំណងជើងថា តើអ្នកអាចឃើញខ្ញុំដែរឬទេ (CYSM) ស្តីអំពីការជួញដូរកម្លាំងពលកម្ម របស់អង្គការអេ២១ https://www.youtube.com/watch?reload=9&v=DELqLm1xFD0

សូមទាញយកសៀវភៅណែនាំមាតាបិតារបស់អង្គការអេ២១
ដើម្បីជជែកជាមួយកូនរបស់អ្នកអំពីអំពើជួញដូរមនុស្ស៖
A21.ORG/EDUCATION